ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-May-2016, 11:34
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៣៩៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រី រតនៈ

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោក ផាន វ៉ាន (2-TCW-1011) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ផាន វ៉ាន** (2-TCW-1011)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ៣
សួរដោយលោក ចូសេហ្វ អេនឌ្រូ បិយលី ផ្ដើមពី........................................ ទំព័រ ៦
សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្ដើមពី........................................ ទំព័រ ៣២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................ ទំព័រ ៤៤
សួរដោយលោក គង់ សំអុន ផ្ដើមពី ........................................ ទំព័រ ៥៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1011 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិ-សុខភ្នំក្រោល។ ហើយការធ្វើសវនាការនេះ គឺការស្ដាប់សក្ខីកម្មសាក្សីតាមរយៈប្រព័ន្ធសោតទស្សន៍ ពីខេត្តបន្ទាយមានជ័យ។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការ រួមទាំងការរៀបចំប្រព័ន្ធសោតទស្សន៍នៅទីកន្លែងដែលរៀបចំពីខេត្តបន្ទាយមានជ័យផង។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន លើកលែងតែលោកស្រី ម៉ារី ហ្គីរ៉ូដ៍ មេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានជូនដំណឹងមកថា អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-1011 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបន្ទាយមានជ័យ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។

តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះបានរៀបចំរួចរាល់ហើយ។ រីឯសាក្សីក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនេះផងដែរ។ សាក្សីបានធ្វើសម្បថរួចហើយ មុននឹងចូលមកផ្តល់សក្ខីកម្ម។

សូមអរគុណលោកប្រធាន។

[០៩:០៣:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដែលគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរបណ្តាលឲ្យឈឺកាន់តែខ្លាំង និងវិលមុខម្តងៗ និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការ

សម្រាប់ថ្ងៃនេះ។

សួស្តី លោក ញ៉ែម សំណាង! តើលោកបានរៀបចំប្រព័ន្ធសោតទស្សន៍រួចរាល់ហើយនៅ?

**លោក ជួង សុភារិទ្ធ៖**

បាទ លោកប្រធាន ខាងយើងខ្ញុំបានរៀបចំប្រព័ន្ធសោតទស្សន៍រួចរាល់អស់ហើយ។

[០៩:០៥:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ ហើយសួស្តី លោកសាក្សី តើលោកបានត្រៀមខ្លួនរួចរាល់ហើយនៅ?

**លោក ផាន វ៉ាន៖**

**ផ៖** បាទ ជម្រាបសួរ។ បានរៀបចំរួចហើយ។

**ស៖** បាទ ហើយសួស្តីលោកសាក្សី តើលោកឈ្មោះអី?

**ផ៖** ឈ្មោះ ផាន វ៉ាន។

**ស៖** លោកប្រើឈ្មោះ ផាន វ៉ាន ហ្នឹង ជាផ្លូវការនៅក្នុងអត្តសញ្ញាណ គាត់ធ្វើ -- លោកបានធ្វើអត្តសញ្ញាណប័ណ្ណពលរដ្ឋខ្មែរដែរឬទេ សព្វថ្ងៃនេះ?

**ផ៖** ធ្វើហើយបាទ។ ឈ្មោះ ផាន វ៉ាន ឈ្មោះជាផ្លូវការ។

**ស៖** ហើយចុះឈ្មោះ ខាំ ផាន់ ហ្នឹង យ៉ាងម៉េចវិញ?

**ផ៖** ខាំ ផាន់ ហ្នឹង ឈ្មោះដើម តាំងពីកំណើតមក។

**ស៖** អ៊ីចឹង យើងប្រើឈ្មោះលោក គឺឈ្មោះជាផ្លូវការ ផាន វ៉ាន អ៊ីចឹងម្អេស?

**ផ៖** ផាន វ៉ាន។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណា លោក ផាន វ៉ាន?

**ផ៖** ចាំតែឆ្នាំ ឆ្នាំ១៩៦០។

[០៩:០៦:៣០]

**ស៖** អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ផ៖** នៅភូមិជីមៀត ឃុំជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។

**ស៖** ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ផ៖** នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

**ស៖** លោកប្រកបមុខរបរអ្វីដែរ?

**ផ៖** ធ្វើចម្ការ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកឈ្មោះអី?

**ផ៖** ឪពុកបង្កើតឈ្មោះ ឈ្មោះបដិវត្តន៍ហ្នឹង ឈ្មោះ ឡាំង។ ឈ្មោះពីដើមឈ្មោះ សុវណ្ណ ហើយម្តាយឈ្មោះ ខាំ កន។

**ស៖** ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ផ៖** ភរិយាឈ្មោះ ហ៊ុន ឆវី ហើយកូនបីនាក់។

**ស៖** អរគុណ។ លោក ផាន វ៉ាន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ទេ ក៏ដូចជាបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៃរឿងក្តីនេះទេ។ តើរបាយការណ៍នេះ ត្រឹមត្រូវដែរឬទេ?

**ផ៖** ត្រឹមត្រូវបាទ។

[០៩:០៨:០៤]

**ស៖** ហើយតាមសេចក្តីរាយការណ៍របស់ក្រឡាបញ្ជីអម្បាញ់មិញនេះ ថាលោកបានស្បថចំពោះមុខវត្ថុស័ក្តិសិទ្ធិរួចហើយ មុននឹងពេលដែលលោកមកកាន់កន្លែងផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នេះ។ តើពិតមែនដែរទេ?

**ផ៖** ពិតប្រាកដ។

**ស៖** ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចលោក ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក ផាន វ៉ាន ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឱ្យលោកធ្វើអត្ថាធិប្បាយ -- លោកមានសិទ្ធិបដិសេធទៅនឹងការសួរ ឬក៏ការសុំធ្វើអត្ថាធិប្បាយដែលនាំឱ្យចម្លើយនោះដាក់បន្ទុកលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះត្រូវតែឆ្លើយ

រាល់សំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតប ឬការសេចក្ដីរៀបរាប់ធ្វើអត្ថាធិប្បាយនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចជាយើងប្រាប់អំពីសិទ្ធិរួចហើយ អម្បាញ់មិញនេះ។

ហើយក្នុងឋានៈជាសាក្សីត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុនូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធសំណួរដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

លោក ខាំ ផាន់ តើ -- អ៎! លោក ផាន វ៉ាន តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណាខ្លះ?

**ផ៖** ធ្លាប់ធ្វើនៅចម្ការខ្ញុំ ហើយនិងធ្វើនៅម៉ាឡៃ។

[០៩:១០:០១]

**ស៖** លោកចាំថាធ្វើប៉ុន្មានដងទេ ហើយធ្វើនៅអំឡុងពេលណាដែរទេ គ្រាន់តែប្រាប់ឆ្នាំក៏បានដែរ ប្រសិនបើចាំ?

**ផ៖** អត់ចាំឆ្នាំផង តែចាំ ដូចថាធ្វើបើមិនបីដង គឺបួនដង។

**ស៖** បាទ ហើយមុននឹងពេលចូលមកអង្គុយទីនេះ អង្គុយទីនោះ ដើម្បីផ្ដល់សក្ខីកម្ម តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ផ៖** បានអានខ្លះដែរ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្ម ដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺវាពិតជាត្រឹមត្រូវ សមស្របស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុន ដែលលោកថាបីដង ឬបួនដង ធ្វើនៅចម្ការរបស់លោកនោះដែរឬទេ?

**ផ៖** អត់ច្បាស់ផង ស្ដាប់អត់ច្បាស់។

**ស៖** ក្រោយពីលោកអាននូវកំណត់ហេតុទាំងអស់នោះ តើកំណត់ហេតុដែលលោកបានអានពេលមុននេះ បន្តិចនេះ ដែលប្រៀបធៀបទៅនឹងសក្ខីកម្មដែលលោកបានផ្ដល់ចំនួនបីលើក ឬបួនលើក

01239085



កាលពីពេលមុន នៅនឹងចម្ការរបស់លោកនោះ តើវាមានខ្លឹមសារ សមស្របស៊ីសង្វាក់គ្នាដែរឬទេ?

**ឆ៖** សមស្របបាទ។

**ប្រធានអង្គជំនុំ៖**

បាទ នៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក. អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលសាក្សី ផាន វ៉ាន មុនភាគីដទៃនៃរឿងក្តី។ ហើយសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានពេលរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១១:៥៦]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហការីទាំងអស់ សាធារណជនទាំងក្នុង ក្រៅបន្ទប់សវនាការ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំឈ្មោះ អេនឌ្រូ ប៊ិយ ខ្ញុំគឺជាសហព្រះរាជអាជ្ញារងនៃការិយាល័យសហព្រះរាជអាជ្ញា។ ដំបូងខ្ញុំសួរថា លោកស្តាប់ខ្ញុំបានច្បាស់ទេលោក?

**លោក ផាន វ៉ាន៖**

**ឆ៖** ស្តាប់បានហើយបាទ។

**ស៖** លោកសាក្សី បីបួនឆ្នាំកន្លងមកនេះ លោកបានផ្តល់សក្ខីកម្មពីរថ្ងៃនៅមុខអង្គជំនុំជម្រះនៅថ្ងៃទី១១ ទៅដល់ថ្ងៃ១៤ ខែធ្នូ ២០១២។ ខ្ញុំជៀសវាងមិនសួរសំណួរដែលលោកបាន<>ឆ្លើយហើយនោះទេ។ គ្រាន់តែសួរលោកបញ្ជាក់ទៅលើប្រធានបទមួយចំនួនដែលលោកបានឆ្លើយរួចមកហើយ ថាសួរបញ្ជាក់ឲ្យបានច្បាស់លាស់តែប៉ុណ្ណោះ។ ខ្ញុំចាប់ផ្តើមសួរលោកអំពីមន្ទីរក-១៧ ដែលលោកធ្លាប់ធ្វើការនៅទីនោះ នៅពេលដែលលោកមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ លោកថាលោកធ្វើការជាអ្នក<បកប្រែសារទូរលេខ> សម្រាប់ឪពុករបស់លោកឈ្មោះ ឡាំង <ដែលជាលេខា>នៅតំបន់១០៥ នៅមន្ទីររបស់គាត់ ឈ្មោះថាមន្ទីរក-១៧។ តើ<អាចរៀបរាប់ពីសភាពខាងក្រៅរបស់>មន្ទីរក-១៧

<ជូនតុលាការស្ដាប់បានទេ? តើមានអគារប៉ុន្មាន ហើយតើអគារទាំងនោះ>នៅជិតគ្នាប៉ុនណាដែរ?

[០៩:១៣:៥៩]

**ផ៖** ក-១៧ ហ្នឹង គឺថាគេហៅមន្ទីរតំបន់ហ្នឹងតែម្ដង នៅៗជាមួយគ្នាហ្នឹង។

**ស៖** ហើយមន្ទីរក-១៧ តើមានតែអគារតែមួយទេ ឬក៏អាចមានអគារច្រើន?

**ផ៖** មានអគារតែមួយ។

**ស៖** ដូច្នេះ តើត្រឹមត្រូវដែរទេថា នៅពេលដែលលោកធ្វើការនៅមន្ទីរបកប្រែទូរលេខជាមួយ <ឪពុកលោក គឺ>លោកធ្វើការនៅក្នុងអគារតែមួយជាមួយឪពុករបស់លោកមែនទេ?

**ផ៖** នៅអគារតែមួយ -- មិនមែនអគារដូចសម័យឥឡូវទេ ជំនាន់ហ្នឹង កន្លែងអគារ អាកន្លែងគេធ្វើការ កន្លែងប្រជុំ តែយើងធ្វើការបកសារទូរលេខហ្នឹងនៅខាងផ្ទះខ្ទម ជំនាន់ហ្នឹងមិនទាន់មានអគារអីទេ កាលហ្នឹង។ អគារមានតែនៅគេហៅមន្ទីរ១៧ហ្នឹង អគារធំមួយ ដូចសាលប្រជុំអីចឹង ផ្ទះឈើលើថ្មក្រោម ឯអ្នកធ្វើការបកសារ បកអី បកតាមផ្ទះតូចៗ ដែលគេនៅក្នុងមន្ទីរហ្នឹង។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ដើម្បីឲ្យខ្ញុំយល់បានឲ្យច្បាស់លាស់ កាលណា<លោក>និយាយពីមន្ទីរ ក-១៧ លោកនិយាយសំដៅទៅលើអគារ<ជាក់លាក់>មួយ ក៏ប៉ុន្តែវាមានបរិវេណនៅជុំវិញ<ក-១៧ ដែល>មានផ្ទះ<ជាច្រើន>ដែលបម្រើកិច្ចការ<ផ្សេងៗ>ជួយទៅដល់មន្ទីរក-១៧។ ត្រឹមត្រូវដែរទេ?

**ផ៖** ត្រឹមត្រូវ។

**ស៖** បរិវេណជុំវិញមន្ទីរក-១៧ ដែលលោកកំពុងតែនិយាយនេះ តើបរិវេណមន្ទីរក-១៧ទាំងមូលហ្នឹងមានទំហំប៉ុនណាដែរ? <តើមានអគារប៉ុន្មាន?>

**ផ៖** ទំហំមានទំហំធំដែរហ្នឹង ប្រហែលជា បើមិន ៥ ទៅ ១០ហិកតា។

**ស៖** អគារដែលឪពុករបស់លោកធ្វើការ ដែល<ខ្ញុំប្រមូលព័ត៌មានបានគឺ>មន្ទីរ<ក->១៧នេះ សូមលោករៀបរាប់អគារមន្ទីរ ក-១៧ នេះ ឲ្យបានលម្អិតជូនអង្គជំនុំជម្រះបន្តិចបានទេ?

[០៩:១៧:០១]

**ផ៖** មន្ទីរក-១៧ ហ្នឹង គឺអគារហ្នឹងធ្វើអគារមួយសម្រាប់ប្រជុំ កន្លែងៗប្រជុំនៅលើកំពូលភ្នំក្រោលហ្នឹងតែម្ដង នៅលើភ្នំក្រោល។ ហើយខាងៗអគារហ្នឹង តាមផ្លូវមានផ្ទះៗ ខ្ទមតូចៗនៅដង្ហែផ្លូវតាំងពីទំនប់ទឹកឡើងមកជើងភ្នំមកលើមក ហើយតាមៗខ្នងភ្នំហ្នឹងធ្វើភូមិ ធ្វើភូមិបណ្ដោយ ដាំដើមគីនីនដាំអី ជាភូមិមួយតែម្ដង មន្ទីរហ្នឹងយើងហៅភូមិៗហ្នឹងឯង។ តែជំនាន់នឹងគេហៅមន្ទីរ គេយកប្រជាជន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01239087



យកអី អ្នកមានគ្រួសារដាក់ដោយឡែក នៅអ្នកនៅលីវនៅផ្ទះជុំគ្នាទៅ ផ្ទះប្រក់ស្បូវខ្លះ ប្រក់ស័ង្កសីខ្លះ ហើយផ្ទះរាប់រយខ្នង។ បាទ សូមបញ្ជាក់។

**សៈ** មន្ទីរក-១៧ ដែលឪពុករបស់លោក<រស់នៅ>ហ្នឹង <តើនេះ>គឺជាអគារមួយ<ដែលមានកន្លែង>ប្រជុំនៅទីនោះ <ដែលលោកទើបតែបញ្ជាក់មិញនេះ> ឬក៏វាជាអគារដាច់ដោយឡែក<?>

**ផៈ** អគារនឹងកន្លែងប្រជុំៗប្រចាំការតែម្តង រាល់ខែគេមកជួបជុំគ្នាប្រជុំនៅប្រជុំ ពួកចៅហ្វាយស្រុក ពួកអីហ្នឹងមក ខាងគណៈស្រុកគណៈអីហ្នឹងគេមកប្រជុំកន្លែងមន្ទីរ១៧ ដែលនៅអគារហ្នឹងតែម្តង។

**សៈ** តើអគារនឹងមានប៉ុន្មានជាន់? មានពីរជាន់ បីជាន់ ឬក៏ប៉ុន្មានជាន់?

**ផៈ** ពីរជាន់ ជាន់ក្រោមៗស៊ីម៉ងត៍ ជាន់លើឈើ។

**សៈ** តើមន្ទីរសារទូរលេខមានចម្ងាយប៉ុន្មានពីមន្ទីរក-១៧ ដែលគេប្រារព្ធកិច្ចប្រជុំដែលជាកន្លែងឪពុករបស់លោកធ្វើការហ្នឹង?

**ផៈ** ប្រហែលជា ១០០ម៉ែត្រជាងបាទ។

[០៩:១៩:៥៦]

**សៈ** នៅពេលដែលលោកបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកន្លងមកហើយនោះ លោកថាលោកធ្វើការនៅមន្ទីរ<>សារទូរលេខ<នៅក-១៧> ពីចុងឆ្នាំ<៧៥> (សុំទោស) ពីឆ្នាំ៧៤ រហូតដល់ចុង៧៥ <ឬ>ដើមឆ្នាំ៧៦ <នៅពេលដែល>ប្អូនស្រីរបស់លោកបន្តកិច្ចការនេះ ហើយលោកក៏ក្លាយទៅជាអ្នកបើកបរឲ្យឪពុករបស់លោក។ ត្រឹមត្រូវដែរទេ?

**ផៈ** ត្រឹមត្រូវ។

**សៈ** ហើយក្រោយ<ពីរយៈពេលនោះ គឺនៅ>ចុងឆ្នាំ៧៥ <ឬ>ដើមឆ្នាំ៧៦ ពេលលោកធ្វើជាអ្នកបើកបរឲ្យឪពុករបស់លោក។ តើលោកមានបានវិលត្រឡប់មកធ្វើការនៅមន្ទីរ<សារ>ទូរលេខនេះវិញក្នុងរយៈពេលណាមួយដែរទេ?

**ផៈ** អត់បានធ្វើទេ ធ្វើតែបើកបរតែមួយមុខ។

**សៈ** តើលោកអាចជម្រាបជូនតុលាការបានទេថា កិច្ចការប្រចាំថ្ងៃរបស់លោកដែលលោកធ្វើជាអ្នកបើកបរហ្នឹង គឺតើលោកធ្វើអ្វីខ្លះ កិច្ចការប្រចាំថ្ងៃនុ៎ង?

**ផៈ** ក្រៅពីបើកបរ មានតែដាំ ធ្វើការងារពលកម្ម ដាំដុះផ្សេងៗ។

**សៈ** តើលោកបើក<ឡាន>ជូនឪពុកលោកទៅកន្លែងណាខ្លះ ពេលដែលលោកធ្វើជាអ្នកបើក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បរនោះ?

**ឆ៖** ដូចចាំមិនបានដែរហ្នឹង។ ទៅច្រើន ទៅតាមស្រុក តាមអ៊ីចឹងទៅ។

**ស៖** តើលោកមានដែលបើកជូនគាត់ទៅអគារ<ផ្សេងៗនៅជិត>ក-១៧ដែរទេ ក្រៅពីបើកជូនគាត់ទៅតាមបណ្ដាស្រុកហ្នឹងណា<>?

**ឆ៖** គាត់នៅហ្នឹងឯង អត់បានជូនទៅណា បើគាត់នៅៗមន្ទីរក-១៧។

**ស៖** ខ្ញុំសូមទោស សំណួរខ្ញុំវាមិនច្បាស់លាស់។ តើលោកមានបានបើកជូនគាត់ទៅកាន់អគារដទៃៗណាទៀតដែលនៅជិតមន្ទីរក-១៧ ដែរទេ? ហ្នឹងមិននិយាយអំពីការបើកជូនគាត់ទៅតាមបណ្ដាស្រុកទេ ថាមានបើកជូនគាត់ទៅអគារណាមួយនៅជិតៗក-១៧ ដែរទេ?

**ឆ៖** អត់មានទេ បាទ។

**ស៖** នៅពេលលោកធ្វើជាអ្នកបើកបរឲ្យឪពុករបស់លោក ហើយឪពុករបស់លោកនៅ<>មន្ទីររបស់គាត់នៅក-១៧។ នៅពេលដែលលោករង់ចាំគាត់ហ្នឹង តើលោកសម្រាកនៅកន្លែងណាដែរ <បើគាត់ត្រូវការលោកឲ្យបើកជូនគាត់ទៅកន្លែងណាមួយនោះ>? <តើ>សម្រាកនៅ<>មន្ទីរក-១៧ តែម្ដង <ឬក៏លោកស្នាក់នៅអគារផ្សេងទៀតនៅជិតនោះ>?

[០៩:២៤:០៧]

**ឆ៖** សម្រាកអគារផ្សេង តែនៅក្នុងមន្ទីរ១៧ហ្នឹង។

**ស៖** តើអគារដែលលោកសម្រាកហ្នឹង វាមានចម្ងាយប៉ុន្មានពី<មន្ទីរ>ក-១៧?

**ឆ៖** វានៅក្នុងមន្ទីរក-១៧ ហ្នឹងន៎ មន្ទីរហ្នឹងវាទំហំវាធំ។ ជុំវិញហ្នឹង ផ្ទះតូចៗៗហ្នឹង គេហៅមន្ទីរ រួមទាំងអគារធំហ្នឹងផង។ ប៉ុនមិនឆ្ងាយប៉ុន្មានទេ ពីៗអគារដែលៗសាលប្រជុំគេហ្នឹង ប្រហែលជា១០០ម៉ែត្រជុំវិញហ្នឹងឯង។

**ស៖** នៅពេលលោកមកឆ្លើយជូនតុលាការ<កាលពីមុននោះ លោកបានឆ្លើយ>យ៉ាងវែងឆ្ងាយស្ដីអំពីដំណើរដែលលោកមកកាន់ទីក្រុងភ្នំពេញជាមួយឪពុករបស់លោក នៅពេលដែលគាត់ត្រូវបានគេសម្លាប់ ខ្ញុំនឹង<>មិន<>សួរចំណុចនេះឡើងវិញទេ ក៏ប៉ុន្តែខ្ញុំសូមឲ្យបញ្ជាក់ ថាតើលោកនៅធ្វើការជាអ្នកបើកបរឲ្យឪពុករបស់លោករហូតដល់លោកមកភ្នំពេញជាមួយឪពុកហ្នឹងរហូតដល់ពេលដែលគេសម្លាប់គាត់តែម្ដង។ អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ នៅបើកឡានឲ្យគាត់រហូតដល់ពេលគាត់ស្លាប់នៅភ្នំពេញ។

**សះ** លោកចាំខែ ឆ្នាំដែលឪពុករបស់លោកបានមកភ្នំពេញជាចុងក្រោយដែរទេ?

**ធះ** អត់ចាំផងបាទ អត់ចាំថ្ងៃខែច្បាស់ទេ ឆ្នាំៗហ្នឹងដូចជាឆ្នាំ៩០ ហ៎! -- ៨០ ឬ៧០ ទេភ្លេចបាត់ហើយ អត់ចាំផង បាទ។

**សះ** ខ្ញុំសូមអានសម្រង់នូវ<>ចម្លើយរបស់ប្អូនស្រីលោកឈ្មោះ ហាន គឺឆ្លើយជូនសហចៅក្រមស៊ើបអង្កេត E3/44, ERN អង់គ្លេស 00295164, ខ្មែរ 00287715, បារាំង 00353129។ នេះគឺអ្វីដែលប្អូនស្រីរបស់លោកឆ្លើយ សូមដកស្រង់៖ "គេហៅឪពុកខ្ញុំឲ្យទៅភ្នំពេញនៅ<>ខែតុលា ៧៧"។ តើចំណុច<នេះ>ជួយរំឭកដល់ការចងចាំរបស់លោកទេ ថាលោកនេះបានធ្វើដំណើរមកភ្នំពេញជាមួយឪពុករបស់លោក ហើយនៅពេលនោះគឺថាគេបានសម្លាប់ឪពុករបស់លោក គឺនៅខែតុលា ឆ្នាំ១៩៧៧?

[០៩:២៧:៣១]

**ធះ** ខ្ញុំចាំអត់បានផង គ្រាន់តែថាមកហ្នឹងមកជាមួយគ្នា វាចុង៧៦ ឬក៏ដើម៧៧ ខ្ញុំចាំមិនច្បាស់ទេ។ អាហ្នឹងសូមបញ្ជាក់ថាមិនមែនៗប្អូនខ្ញុំទេ គឺថាបងៗស្រីខ្ញុំគាត់នៅខាងៗធ្វើសារទូរលេខហ្នឹង កាលជំនាន់ហ្នឹង មិនមែន -- សូមបញ្ជាក់ថាមិនមែនប្អូនទេ បងស្រីៗឈ្មោះៗ ឫ ផាន់ ឈ្មោះដើម ឈ្មោះឥឡូវឈ្មោះ ហាន។ សូមបញ្ជាក់ប៉ុណ្ណឹង។

**សះ** ត្រឹមត្រូវហើយ គឺបងស្រីដែលជំនួសការងារលោកនៅមន្ទីរបកប្រែទូរលេខ សូមទោស។ តើលោកអាចប៉ាន់ប្រមាណបានទេ មានមនុស្សប៉ុន្មាននាក់ធ្វើការនៅមន្ទីរក-១៧ គឺថាក្នុងមួយបរិវេណហ្នឹងតែម្តង?

**ធះ** អត់យល់ន័យសួរ ដែលៗសួរអ្នកបកសារ ឬក៏បុគ្គលិកនៅក្នុងមន្ទីរទាំងអស់? បើនិយាយអ្នកបកសារទូរលេខហ្នឹងមានគ្នាតិចទេ មានពីរនាក់ បីនាក់តែប៉ុណ្ណឹងឯង តែបើបុគ្គលិកដែលធ្វើការនៅក្នុងមន្ទីរក-១៧ ហ្នឹងវាមានច្រើនៗផ្នែក មានពួកផ្នែកដឹកជញ្ជូន ផ្នែកខាងទទួលខាងសាលាអប់រំអីៗហ្នឹងវាច្រើនផ្នែកទៀត អាហ្នឹងទាល់លម្អិត និយាយអត្ថាធិប្បាយយូរបានយល់គ្នា ពីព្រោះជំនាន់ហ្នឹងវារចនាសម្ព័ន្ធវាមិនមែនដូចយើងឥឡូវទេ ដូចគេទេ គេថាធ្វើតាមរចនាសម្ព័ន្ធជំនាន់ហ្នឹង ធ្វើខុសគ្នាបាទ។

**សះ** យើងខ្ញុំមិនមានពេលវេលាច្រើនទេលោក សូមឲ្យលោកពន្យល់សង្ខេបជូនតុលាការអំពីរចនាសម្ព័ន្ធ និយាយអំពីអង្គភាពផ្សេងៗដែលប្រតិបត្តិការ<នៅ>ក-១៧ ហើយលោក<នៅចាំពីចំនួនទូទៅ ឬ>ប៉ាន់ប្រមាណចំនួនមនុស្សសរុបតែម្តង <ដែល>ធ្វើការ<នៅ>មន្ទីរក-១៧ <និងអគារនៅជុំវិញនោះ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គឺរចនាសម្ព័ន្ធនៅក-១៧ហ្នឹង ជំនាន់ហ្នឹងវាមានកន្លែងមន្ទីរអប់រំ ជាមន្ទីរអប់រំហ្នឹងរបស់ ក-១៧ហ្នឹង មានខាងផ្នែកទទួលភ្ញៀវ និងទទួលធ្វើបាយធ្វើទឹក មានខាងដាំបាយ ខាងដាំបន្លែ ខាងធ្វើស្រែ ហើយពួកដឹកជញ្ជូន ហើយឡានៗហ្នឹងមានពួកឡានដឹកជញ្ជូនភ្ញៀវដែលមករៀនសូត្រអីៗហ្នឹង។ វាមានច្រើនផ្នែកអ៊ីចឹងបាទ។

**សៈ** ចុះចំនួនកម្មាភិបាលសរុបធ្វើការនៅអង្គភាពនីមួយៗនោះ សុរបគ្នាទាំងអស់ ដែលថាបម្រើការងារឲ្យមន្ទីរក-១៧ ហ្នឹង មានប៉ុន្មាននាក់ដែរ?

**ឆ៖** តាមខ្ញុំចាំមិនច្បាស់ ព្រោះប្រហែលជិត១.០០០នាក់ ទាំងអស់។ ហ្នឹងទាំងក្មេងទាំងចាស់ ទាំងអ្នកធ្វើការទាំងអស់ រួមនៅក-១៧ ហ្នឹងទៅ។

**សៈ** នៅក្នុងអគារនៃមន្ទីរក-១៧ គឺអគារ<ពីរជាន់>ដែលឪពុករបស់លោកធ្វើការនុំង <តើលោកអាចប៉ាន់ស្មានបានទេថាតើ>មានមនុស្សប៉ុន្មាននាក់ធ្វើការក្នុងអគារនុំង?

**ឆ៖** មានតែពីរបីនាក់ទេ អ្នកធ្វើការបម្រើនៅហ្នឹង មានអ្នកដាំបាយមានអីទៀត សរុបទៅវាខ្ទង់ប្រហែលជាជិត២០នាក់។

[០៩:៣២:០០]

**សៈ** តើក្រៅពីអ្នកដាំបាយជាដើម។ល។ <តើលោកអាចប្រាប់ឈ្មោះបុគ្គលម្នាក់ៗដែល>ធ្វើការនៅក្នុងមន្ទីរក-១៧<>ជាមួយឪពុករបស់លោកហ្នឹង<បានទេ? ហើយប្រាប់ផងថា តើពួកគេមានតួនាទីអ្វីខ្លះ>?

**ឆ៖** កម្មាភិបាលមានតែឪពុកខ្ញុំទេ ប្រធានមន្ទីរនៅហ្នឹង។ មានតែប៉ុណ្ណឹងឯង ក្រៅពីហ្នឹងគេមកម្តងម្កាលពេលមកប្រជុំ មករៀនសូត្រហ្នឹង បានកម្មាភិបាលរងខេត្ត រង -- ជំនាន់ហ្នឹង គេហៅអនុគណៈតំបន់អីហ្នឹង បានមកៗសម្រាកនៅហ្នឹង ដូចថាគេមករៀនសូត្រក្នុងរយៈ១៥ថ្ងៃ ឬក៏ មួយអាទិត្យ ឬក៏បីថ្ងៃអ៊ីចឹង បានគេមកស្នាក់នៅហ្នឹង។ ដល់រួចពីហ្នឹង គេជូនគេទៅកន្លែងវិញ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**សៈ** តើលោកចាំឈ្មោះប្រធានមន្ទីរ ឬក៏អនុប្រធានមន្ទីរ <ឬក៏អ្នកណាផ្សេងទៀត>ដែលស្នាក់នៅមន្ទីរក-១៧ ហ្នឹងលោកនៅចាំឈ្មោះបានទេ?

**ឆ៖** ចាំបានតែប្រធានបាទ ប្រធានមន្ទីរហ្នឹង គឺឈ្មោះ ធិន។

**សៈ** តើលោកបានដឹងដែរឬទេ នៅពេលដែលនៅតំបន់១០៥ ថាមានគុក ឬក៏មានមន្ទីរសន្តិសុខណាមួយដែរឬទេ នៅក្នុងតំបន់នោះ?

**ឆ៖** កាលជំនាន់ហ្នឹង គេមិនហៅគុកទេ ឮមានថា មន្ទីរសន្តិសុខ។

**ស៖** <> តើមន្ទីរសន្តិសុខនោះមានឈ្មោះអ្វី?

**ឆ៖** មន្ទីរសន្តិសុខជំនាន់ខ្ញុំនៅហ្នឹង គឺមានឈ្មោះ ពូសុភា<>។

**ស៖** តើមន្ទីរសន្តិសុខនោះនៅឆ្ងាយប៉ុន្មានពីមន្ទីរក-១៧?

**ឆ៖** នៅឆ្ងាយដែរ វានៅខាងត្បូងភ្នំក្រោល ចម្ងាយពីក-១៧ ខ្ទង់ជាង១០គីឡូបាទ។

**ស៖** នៅពេលដែលលោកនិយាយពីមន្ទីរសន្តិសុខថា ពូសុភា នោះ តើលោកនិយាយថា សំដៅថា ប្រធានមន្ទីរដែលជាអ្នកទទួលបន្ទុក<គ្រប់គ្រងមន្ទីរ>ហ្នឹង<មែន>ទេ<>?

**ឆ៖** ពូសុភា ហ្នឹង វា អាហ្នឹងគាត់ប្រធានមន្ទីរសន្តិសុខហ្នឹងតែម្តង។

[០៩:៣៥:៣៧]

**ស៖** លោកសាក្សី យើងនៅក្នុងសំណុំរឿងគឺរបាយការណ៍កំណត់ទីតាំង គឺថា <E3/8057>, ខ្មែរ ERN 00371404, អង់គ្លេស 00365620 ហើយបារាំង 00371275។ ដែលមានផែនទីនៃមន្ទីរសន្តិសុខដែលដឹកនាំដោយ ពូសុភា <>ក-១១ <ក៏ដូចជា ក-១៧>។ របាយការណ៍កំណត់ទីតាំងនេះនិយាយថា ទីតាំងនេះក-១១ ហើយនិងក-១៧ ស្ថិតនៅ<>"ប្រហែលជាក្នុងរវាង១គីឡូម៉ែត្រពីគ្នា"។ <តើវាធ្វើឲ្យលោក>ចងចាំ<ឡើងវិញទេ>ថា តើមន្ទីរសន្តិសុខដែលរៀបរាប់នេះគឺស្ថិតនៅជិតក-១៧ <ជាង មិនមែនចម្ងាយ>១០គីឡូម៉ែត្រ<>ដូចដែលលោករៀបរាប់ហ្នឹង<>ទេ?

**ឆ៖** អាហ្នឹងទាល់មើលៗផែនទីថា បើគិតក្រឡាត្រង់អាចៗជិតជាង ប៉ុន្តែជំនាន់ហ្នឹងផ្លូវៗកោងផ្លូវវង់ មិនមែនផ្លូវកាត់ត្រង់ទៅៗអ៊ីចេះបានទេ វង់មកៗលិចមកបានចាក់មកកើតវិញ បានទៅដល់មន្ទីរៗសន្តិសុខ វាម្ខាងជើងភ្នំម្នាក់។ មន្ទីរសន្តិសុខហ្នឹង វានៅជើងភ្នំខាង បើតាមខ្ញុំចាំដូចជាខាងៗត្បូងៗភ្នំក្រោល។ សូមបញ្ជាក់ត្រង់ហ្នឹងបាទ ហើយចម្ងាយហ្នឹងវា ដូចថាគឺតាមផ្លូវហ្នឹងវាកោងតាមផ្លូវដែលប្រើហ្នឹងខ្ទង់១០គីឡូ ដែលថាទៅត្រង់តែម្តងហ្នឹងមិនដឹងប៉ុន្មានទេ ផ្លិតត្រង់ ខ្ញុំមិនច្បាស់ដែរបាទ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ បន្ថែមលើមន្ទីរសន្តិសុខដែលដឹកនាំដោយ តាសុភានេះ។ តើលោកស្គាល់មន្ទីរសន្តិសុខណាដែលស្ថិតនៅ<>ជិតអាងទំនប់ភ្នំក្រោល ដែលស្ថិតនៅក្រោមបញ្ជារបស់ តាឡេង ដែលស្ថិតនៅក្នុងវរសេនាតូចលេខ២?

**ឆ៖** ខ្ញុំអត់ដែលស្គាល់ផងបាទ ព្រោះសូមបញ្ជាក់ថា កាលជំនាន់ហ្នឹងវាក្រោយពីព្រឹត្តិការណ៍ដែលខ្ញុំចេញពីហ្នឹងហើយហ្នឹង ខ្ញុំអត់ដឹងទេ ព្រោះពីមុនមានតែមួយហ្នឹងទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំចង់ដកស្រង់<ជូន>លោក<ស្តាប់នូវចម្លើយដែលលោក>ដែលឆ្លើយទៅសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/58, អង់គ្លេសERN 00250088, ខ្មែរ 00239936, បារាំង 00283914។ នេះជាអ្វីដែលលោកបាននិយាយកាលនោះ "ឆ្លើយតបទៅនឹង<របាយការណ៍អំពី>សមាសភាពអាក្រក់<សេចក្តីណែនាំរបស់>ក-១៧ គឺ<ថា អ្នកដែលត្រូវ>អប់រំនៅមូលដ្ឋាន គឺ<ប្រព្រឹត្តិ>បទល្មើស<ប្រភេទទី១ និងប្រភេទទី>ពីរ <ហើយ>ហៅទៅអប់រំនៅមន្ទីរសន្តិសុខអាង<ទំនប់>ភ្នំក្រោល<គឺអ្នកប្រព្រឹត្តិបទល្មើសទី៣>។ <>មន្ទីរនេះដឹកនាំដោយប្រធានវរសេនាតូចទី២ ឈ្មោះថា ឡេង"។ អ៊ីចឹងតើលោកសាក្សីនៅចាំដែរឬទេដែលថា<ជាការពិត លោកបានដឹងពី>មន្ទីរសន្តិសុខ<មួយ ដែលគេហៅថាមន្ទីរសន្តិសុខ>អាងទំនប់ភ្នំក្រោល ដែលដឹកនាំដោយ<ប្រធានវរសេនាតូចទី២> ឡេង នេះ។ តើលោកនៅនឹកឃើញមន្ទីរសន្តិសុខហ្នឹងដែរឬទេ?

**ឆ៖** ដូចនឹកមិនឃើញ ដូចអត់មានឈ្មោះ លាង ជាសន្តិសុខទេបាទ។

**ស៖** លោកសាក្សី សហសេវិករបស់ខ្ញុំនឹងបំភ្លឺអំពីឈ្មោះដែលខ្ញុំអានមិនសូវចំតាមឈ្មោះ ជាភាសាខ្មែរ។ អ៊ីចឹងសូមលោកចាំស្តាប់។

[០៩:៤០:៤៩]

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន និងលោក លោកស្រី ចៅក្រម។ តាមរយៈការបកប្រែជាភាសាខ្មែរ ខ្ញុំស្តាប់ឮគាត់បកប្រែថា លាង តាមពិតឈ្មោះមែនទែនគឺ ឡេង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងអត់ទាន់បានទទួលការបកប្រែទៅជាភាសាអង់គ្លេសទេ។

**លោក ស្រ៊ា រតនៈ៖**

ឈ្មោះមន្ទីរមួយដែលលោកសហព្រះរាជអាជ្ញារងអន្តរជាតិបញ្ជាក់ ដែលថាគ្រប់គ្រងដោយប្រធានវរសេនាតូចទី២ ហ្នឹង លោកប្រធានហ្នឹងគាត់ឈ្មោះ ឡេង ជាភាសាខ្មែរ ហើយខ្ញុំស្តាប់ឮការបកប្រែថា ឈ្មោះ លាង។ អ៊ីចឹងជាឈ្មោះពីរផ្សេងគ្នា។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី តាមរយៈការបញ្ជាក់ពីការបកប្រែឈ្មោះថា ឡេង នេះ តើអាចរំឭកការចងចាំដល់លោកទេ អំពីមន្ទីរសន្តិសុខនៅអាងទំនប់ភ្នំក្រោល ដែលដឹកនាំដោយឈ្មោះ ឡេង នេះ ដែរឬទេ?

01239093



**លោក ផាន វ៉ាន៖**

**ឆ៖** ចាំបានបាទ ឡេឿង ហ្នឹង គាត់ក្រោយដក សុភា ហើយបាន តាឡេឿង ហ្នឹងគេមកកាន់ការវិញ។

**ស៖** សូមបំភ្លឺដើម្បីកំណត់ត្រាតុលាការ។ សូមលោកអាចបញ្ជាក់ដែរឬទេ <ថាលោក>ដឹងពីមន្ទីរសន្តិសុខមួយដាច់ដោយឡែក <>នៅក្បែរទំនប់ភ្នំក្រោល ដែលខុសពីមន្ទីរសន្តិសុខមួយដែលដឹកនាំដោយ តាសុភា។

**ឆ៖** សូមបញ្ជាក់ម្តងទៀត ស្តាប់អត់ច្បាស់។

**ស៖** បាទ <>លោកបញ្ជាក់ថា លោកអាចបញ្ជាក់ពីឈ្មោះ មេបញ្ជាការវរសេនាតូចទី២ <តើ>លោកបានដឹងអំពីថាមានមន្ទីរសន្តិសុខមួយទៀតនៅជិតអាងទំនប់ភ្នំក្រោល<ទេ> បាទ?

[០៩:៤៣:២២]

**ឆ៖** មន្ទីរសន្តិសុខនេះ កាលជំនាន់ខ្ញុំនៅមានតែមួយទេ។ ដូចខ្ញុំបញ្ជាក់ខាងលើអ៊ីចឹង បើគិតតាមវង់ មិនមែននៅកន្លែងអាងភ្នំក្រោលទេ មានពីរ មួយអាអាងកន្លែងមន្ទីរក-១៧ អាងមួយ ហើយអាកន្លែងអាងដែលលោកសួរបញ្ជាក់មិញហ្នឹង ខ្ញុំអត់យល់ថាអាងត្រង់ណាទេ គ្រាន់តែថា កន្លែងមន្ទីរសន្តិសុខហ្នឹងវា បើថាគិតពីមន្ទីរ បើមើលភូមិសាស្ត្រពីមន្ទីរក-១៧ ហ្នឹងវានៅខាងត្បូង ខាងត្បូងតាមផ្លូវវាវង់ចាក់មកលិចមក បានចាក់មកកើតវិញវាទៅខាងត្បូង មានតែមន្ទីរហ្នឹងមួយទេកាលជំនាន់ហ្នឹង។ ក្រោយពីដកសុភា ទៅ ពូឡេឿង ហ្នឹងគាត់មកកាន់ទទួលខុសត្រូវ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលលោកនិយាយនៅក្នុងចម្លើយទៅសហចៅក្រមស៊ើបអង្កេត <លោក>ថា <អ្នកដែល>គេហៅ<>ទៅអប់រំ នៅមន្ទីរសន្តិសុខក្បែរទំនប់ភ្នំក្រោលហ្នឹងគឺថា<ជាអ្នកប្រព្រឹត្តិកំហុសប្រភេទទី៣។ តើនោះ>ជាមន្ទីរសន្តិសុខមួយដែលលោកនឹកឃើញពេលនោះ ឬក៏លោក<ចង់និយាយថាលោក>មិននឹកឃើញអំពីមន្ទីរសន្តិសុខ<ដែលលោកប្រាប់សហចៅក្រមស៊ើបអង្កេតនោះទេ>?

**ឆ៖** អត់ខុសទេ អាមន្ទីរជិតមន្ទីរតែមួយទេបាទ។

**ស៖** សូមអរគុណលោកសាក្សីចំពោះការបំភ្លឺ។ តើពេលនោះ តើលោកបានដឹងអំពីមន្ទីរមួយដែលហៅថា ក-១១ ដែលថាជាមន្ទីរឃោធាតំបន់ នៅក្នុងតំបន់១០៥។ តើលោកស្គាល់មន្ទីរហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ អត់ចាំទេ។ អត់ចាំដែរបាទ។ មន្ទីរក-១១ ដូចអត់ៗ ខ្ញុំអត់ស្គាល់ដែរ។ អាហ្នឹងគេរៀបចំក្រោយទៀតយ៉ាងណាមិនដឹងទេ។ កាលជំនាន់មុន ដូចអត់មានទេ មន្ទីរក-១១។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៤៦:០៦]

**ស៖** ខ្ញុំនឹងអានជូនលោកស្តាប់នូវចម្លើយមួយ អំពីរបស់ ប៊ុន ឡឹងចូយ គឺ E3/5178, អង់គ្លេស ERN <00274101>, ខ្មែរ 00197862, បារាំង 00485186។ បុគ្គលនេះបាននិយាយថា <>៖ "អ្នកទោសស្រាលយកទៅឃុំនៅមន្ទីរក-១១ ហើយអ្នកទោសធ្ងន់ទៅដាក់<ភ្នំក្រោល។ ហើយអ្នកទោសដែលអាចកែប្រែបាន គេដាក់នៅណាងឃីលឹក>។ ហើយ ក-១១ គឺជាមន្ទីរ<ឃុំឃាំងបណ្ដោះអាសន្ន> ហើយ<អ្នកជាប់ឃុំត្រូវបញ្ជូនទៅ>ណាងឃីលឹក <បើគេគិតថាអ្នកទោសនោះអាចកែខ្លួនបាន ហើយគេបញ្ជូនទៅ>ភ្នំក្រោល <បើគេចាត់ទុកថាជា>អ្នកទោសធ្ងន់។ ឱកាសនៃការរស់រានជីវិត គឺមានតិចណាស់ ចំពោះអ្នកទោសដែលគេបញ្ជូនទៅភ្នំក្រោល។" លោកសាក្សី តើចំណុចនេះ អាចរំឭកការចងចាំដែរឬទេ<ថាមានមន្ទីរមួយ ដែលគេស្គាល់ថាជា> ក-១១ ដឹកនាំដោយមនុស្សម្នាក់<>ដែលទទួលបន្ទុក<គ្រប់គ្រង>យោធាតំបន់ ហើយ<មាន>មន្ទីរ<សន្តិសុខមួយនៅក្នុងមន្ទីរ>នេះ។ តើលោកអាចនឹកឃើញចំណុចនេះខ្លះៗដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនបានទេ។ កាលជំនាន់ខ្ញុំនៅ ដូចខ្ញុំបញ្ជាក់អ៊ីចឹង អត់មានអាមន្ទីរក-១១ហ្នឹងទេ ហើយ ក-១៧ ហ្នឹង ក៏មិនមែនជាកន្លែងសន្តិសុខដែរ។ ខ្លាចតែពេលក្រោយមកទៀត អាហ្នឹង ខ្ញុំមិនដឹងទេបាទ។

**ស៖** តើលោកនៅចាំដែរឬទេ បុគ្គលដែលគេបញ្ជូនទៅភ្នំក្រោលនេះ <-- ឬក៏ថា តើលោកចាំទេ >មនុស្សភាគច្រើនដែលគេបញ្ជូនទៅទីនោះ អាចរស់រានមានជីវិត<> ហើយអាចត្រឡប់មកវិញបានទេ? ឬក៏ថា <ករណីនោះមិន>ធ្លាប់<កើតមានទេ> ឬក៏<ករណីនោះកើតមានចំពោះអ្នកគ្រប់គ្នាដែលបានចូលទៅគុក>នោះ<>?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី គង់ សំអុន!

[០៩:៤៨:៥៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ សាក្សីបានបញ្ជាក់រួចហើយថា គាត់មិនដឹងពីវត្តមាននៃមន្ទីរភ្នំក្រោលជាមន្ទីរសន្តិសុខទេ នៅពេលដែលគាត់រស់នៅទីនោះ។ ដូច្នេះ ហេតុការណ៍ដែលទាក់ទងទៅនឹងមន្ទីរសន្តិសុខនេះ គឺសាក្សីមិនអាចឆ្លើយបានទេ។ សូមអរគុណបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំជឿជាក់ថា មេធាវីយល់ច្រឡំ<ចំពោះ>សក្ខីកម្ម<នោះហើយ។ នោះមិនមែនជាសក្ខីកម្ម ដែលខ្ញុំបានឮ>បុគ្គលម្នាក់នោះនិយាយ<ទេ។ គាត់និយាយ>ថា គឺថាអាចនឹងមានមន្ទីរសន្តិសុខមួយទៀត បន្ថែមពីលើ<មន្ទីរសន្តិសុខ>ភ្នំក្រោល <ដែលត្រូវបានគេបង្កើតឡើងក្រោយពេលគាត់នៅទីនោះ ប៉ុន្តែ>គាត់បញ្ជាក់<>ថា<ពីវត្តមានរបស់>មន្ទីរសន្តិសុខ<>ភ្នំក្រោល <ដូច>ដែលគាត់ឆ្លើយនៅក្នុងចម្លើយរបស់គាត់ទៅសហចៅក្រមស៊ើបអង្កេត។ ខ្ញុំសូមអនុញ្ញាតបន្តលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកបញ្ជាក់ទៅ គឺការលើកឡើងរបស់សហមេធាវីជាតិ ការពារក្តី លោកខៀវ សំផន គឺត្រឹមត្រូវហើយ គឺគាត់មិនទាន់ មិនបានបញ្ជាក់ ថាគាត់ដឹងអំពីអត្ថិភាពនៃមន្ទីរសន្តិសុខ មន្ទីរក-១១ ទេ។ អំឡុងពេលដែលគាត់នៅ គឺគាត់មិនៗដឹងអំពីការបញ្ជាអត្ថិភាពនៃមន្ទីរសន្តិសុខក-១១ ទេ។ បើលោកសួរអំពីពាក់ព័ន្ធនៅមន្ទីរសុខភ្នំក្រោល ដែលក្រោមការគ្រប់គ្រងរបស់ សុភា ហើយក្រោយមកឈ្មោះឡេងបន្តពី សុភា នោះជាទំនងគាត់ដឹងព័ត៌មាន ពីព្រោះគាត់ដឹងច្បាស់ ហើយគាត់និយាយថា គាត់អំឡុងពេលដែលគាត់ធ្វើការនៅទីនោះ គឺគាត់ដឹងតែមានវត្តមានរបស់មន្ទីរសន្តិសុខតែមួយទេ គេហៅថា មន្ទីរសន្តិ-សុខភ្នំក្រោល។ លោករៀបចំសំណួរឡើងវិញ ហើយបើសិនបើ លោកសួរសំណួរដែលគេ ដែលសាក្សីនេះ មិនដឹងគឺមិនអាចសួរបានទេ សាក្សីមិនអាចឆ្លើយបានទេ មិនអាចឆ្លើយស្មានបានទេ ព្រោះអង្គហេតុនេះ គឺសាក្សីមិនដឹងទេ។

[០៩:៥១:១៦]

**លោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាខ្ញុំបញ្ជាក់មិនត្រឹមត្រូវនៅក្នុងសំណួររបស់ខ្ញុំ ប៉ុន្តែតាមពិត ខ្ញុំយោងទៅរកមន្ទីរសន្តិសុខភ្នំក្រោល <ជាពិសេសគឺខ្ញុំយោងទៅលើសក្ខីកម្មនេះ ដែលខ្ញុំទើបតែអានគឺ>ចម្លើយរបស់ ប៊ុន ឡឹងចូយ <ហើយបុគ្គល>នោះ<>និយាយថា៖ “ឱកាសនៃការរស់រានមានជីវិតហ្នឹង កម្រណាស់ ចំពោះអ្នកដែលគេបញ្ជូនទៅភ្នំក្រោល។” ចប់សេចក្តីដកស្រង់។

**សួរដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី តាមអ្វីដែលលោកដឹង តើសាក្សី ប៊ុន ឡឹងចូយ នោះ និយាយត្រឹមត្រូវដែរ

ឬទេ គាត់ថា អ្នកដែលគេបញ្ជូនទៅភ្នំក្រោល ឱកាសនៃការរស់រានមានជីវិតនោះគឺតិចតួចណាស់?

**លោក ផាន វ៉ាន៖**

**ផ៖** ខ្ញុំមិនបានដឹងច្បាស់ដែរអាហ្នឹង ព្រោះកាលជំនាន់ខ្ញុំនៅវាអត់មានការចាប់ ការចងអីច្រើនទេ អត់មានទេ កាលជំនាន់ហ្នឹង។ ហើយក្រោយពេលហ្នឹង ខ្ញុំអត់យល់ដែរ ព្រោះមិនបានៗឃើញដែរ ក្រោយមកមិនបានដឹងដែរ។

**ស៖** លោកសាក្សីតើលោកធ្លាប់ឮទីកន្លែងមួយឈ្មោះត្រពាំងព្រីងដែរឬទេ? ប្រហែលជានៅ៤គីឡូម៉ែត្រខាងលិចភ្នំក្រោល នៅតាមផ្លូវទៅខេត្តក្រចេះ?

**ផ៖** ស្តាប់មិនច្បាស់នេះ បញ្ជាក់ពីទីកន្លែងហ្នឹងបាទ។

**ស៖** បាទ ការអានរបស់ខ្ញុំហ្នឹង ហៅថា "ត្រពាំងព្រីង"។

**ផ៖** និយាយៗពីស្អីៗបាទ ពីព្រោះស្តាប់ៗមិនច្បាស់ ឮតែត្រពាំងព្រីង។

[០៩:៥៣:២៦]

**ស៖** បាទ ខ្ញុំចង់សួរលោកថា តើលោកដឹងពីទីតាំងមួយ ជាទីកន្លែងគឺថាឈ្មោះត្រពាំងព្រីង តើលោកធ្លាប់ឮអ្វីពីកន្លែងនេះដែរឬទេ?

**ផ៖** កន្លែងហ្នឹងអត់ៗដែលឮទេបាទ។

**ស៖** ខ្ញុំចង់អានជូនលោកស្តាប់នូវចម្លើយមួយជូនលោកស្តាប់ ដើម្បីរំឭកការចងចាំរបស់លោក គឺចម្លើយ អូ.ស៊ី.អាយ.ជេ របស់ សល់ វ៉ា គឺ <E3/5222> ហើយអង់គ្លេស ERN 00242157 ដល់ 58 ខ្មែរ 00236737 ដល់ <38> , បារាំង 00274821 ដល់ 22។ បុគ្គលរូបនេះនិយាយថា សូមដកស្រង់៖ "អ្នកយាមគុកនោះ បានប្រាប់ខ្ញុំថា អ្នកដែលគេចាប់យកទៅ<ដាក់ក្នុងគុកនោះ> គឺយកទៅដាក់គុកតែពីរ ឬបីថ្ងៃទេ។ បន្ទាប់ក្រោយមក គេយកទៅត្រពាំងព្រីងដើម្បីសម្លាប់ចោល។" ហើយនៅបន្ទាប់ទៀតនោះគឺថា "<អ៊ីរូត> ក៏បាននិយាយថា <>អ្នក<ដែល>គេដឹកតាមឡាន ពី<កន្លែង>ផ្សេងៗ<នៅក្នុងតំបន់នោះ ភាគច្រើនត្រូវបាន>គេដឹកទៅត្រពាំងព្រីង។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹង គឺថាអំពីអ្វីដែលខ្ញុំអាននេះរំឭកការចងចាំរបស់លោកអំពីត្រពាំងព្រីងទេ កាលពីលោករស់នៅតំបន់១០៥ កាលនោះ?

**ផ៖** កាលពីជំនាន់ខ្ញុំនៅ អត់ៗមានទេបាទ អត់មានឈ្មោះហ្នឹងទេ ហើយព្រឹត្តិការណ៍ដែលគេធ្លាប់អំមិញហ្នឹង កាលជំនាន់ហ្នឹងក៏ទាន់មានដែលបាទ ហើយក្រោយមកទៀត ខ្ញុំអត់ៗដឹងទេបាទ។

**ស៖** មុននឹងខ្ញុំចូលទៅផ្នែកផ្សេង ខ្ញុំចង់សួរសំណួរមួយទៅលោក សូមឲ្យលោកបំភ្លឺពីអ្វីដែលលោកបាននិយាយ។ នៅក្នុងចម្លើយមួយរបស់លោកគឺថា E3/57, អង់គ្លេស 00290508, ខ្មែរ 00287705 ហើយបារាំង 00353104។ អ្វីដែលលោកនិយាយនោះគឺ សូមដកស្រង់៖ “មន្ទីរសន្តិសុខ <តំបន់>១០៥ ស្ថិតនៅភ្នំក្រោល ស្ថិតនៅក្រោមការដឹកនាំរបស់ តាសុភា (ក៏គេហៅមន្ទីរតាសុភា)ផងដែរ។ វ៉ាន់ បានដឹងច្រើនអំពីរឿង<>មន្ទីរសន្តិសុខនេះ<ច្រើនជាងខ្ញុំ>។” ចប់សេចក្តីដកស្រង់។ សូមលោកប្រាប់តុលាការ តើ វ៉ាន់ ដែលលោកហៅកន្លែងហ្នឹងគឺ វ៉ាន់ មួយណា?

**ឆ៖** វ៉ាន់ ប្អូនខ្ញុំវានៅៗ វានៅភូមិជីមៀតរាល់ថ្ងៃ។ ហើយវា គ្រាន់តែដឹងកន្លែងមន្ទីរសន្តិសុខហ្នឹងក្រោយមកវាដឹងៗ វាដឹងថានៅត្រង់ណា ពីព្រោះវាអ្នកស្រុកហ្នឹង។ ហើយខ្ញុំចេញពីហ្នឹងមកមិនបានទៅនៅស្រុកឯណា។ ក្រោយពី ខ្ញុំចេញមកចេញមកៗរហូត។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** តើ វ៉ាន់ រស់នៅតំបន់ហ្នឹងដែរឬទេ នៅក្នុងសម័យឆ្នាំ១៩៧៥ ដល់ ១៩៧៩ នោះ? ឬក៏នៅក្នុងពេលណាមួយក្នុងរវាងពេលនេះ?

**ឆ៖** កាលជំនាន់ហ្នឹង វ៉ាន់ អត់នៅទេ វ៉ាន់ មកនៅភ្នំពេញ។ ទើបទៅនៅក្រោយនេះទេ វ៉ាន់ បានទៅនៅវិញ។

[០៩:៥៨:១៤]

**ស៖** សូមអរគុណលោកសាក្សី។ តាមអ្វីដែលលោកដឹង តើមន្ទីរក-១៧ ខ្លួនឯងគេធ្លាប់ប្រើជាកន្លែងដើម្បីឃុំខ្លួននរណាម្នាក់ដែលគេចាប់ខ្លួនដែរឬទេ នៅក្នុងឆ្នាំ១៩៧៧?

**ឆ៖** កាលពីជំនាន់ខ្ញុំនៅ អត់ៗមានឃុំខ្លួននៅមន្ទីរ១៧ទេបាទ។ សូមបញ្ជាក់អត់មានទេ ពីព្រោះកន្លែងហ្នឹង កន្លែងរៀនសូត្រធម្មតា។

**ស៖** ការបកប្រែដែលខ្ញុំបានទទួលនោះ លោកនិយាយថា<> មិនមានការឃុំខ្លួនទេនៅមន្ទីរសន្តិសុខនេះ។ ខ្ញុំចង់បានការបំភ្លឺអំពីនៅក-១៧ <>ជាមន្ទីរដែលឪពុក<>របស់លោកធ្វើការ។ ថាតើនៅមន្ទីរក-១៧ នេះមានកន្លែងឃុំខ្លួនមនុស្សដែរឬទេ?

**ឆ៖** អត់មានទេបាទ ជំនាន់ហ្នឹងអត់មានទេ ក្រោយមកទៀតមិនដឹងទេ ប៉ុន្តែជំនាន់ហ្នឹងអត់មាន។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សាក្សីពីរនាក់ ដែលបានមកបំភ្លឺនៅតុលាការនេះបានបញ្ជាក់<>អំពីថា<ពួក>គាត់ជាអ្នកទោសនៅក្រុមអ្នកទោសជាច្រើនដែលទាក់ទងទៅ ខាំ ភួន ហើយ<ត្រូវបានគេចាប់ខ្លួនក្រោយ>ពីការ

ស្លាប់របស់ឪពុកលោក ហើយ<ពួក>គេ<ត្រូវ>បានឃុំខ្លួន<នៅអគារពីរជាន់>នៅក-១៧។ ហើយខ្ញុំដឹងហើយ គឺថាក្រោយពីឪពុករបស់លោកស្លាប់ទៅ លោកមិនបាននៅ<>តំបន់១០៥ទេ។ ណេត សាវ៉ាត <បាននិយាយថា>ប្រហែលជាមួយខែ<មុន គឺ>នៅពេលដែលឪពុករបស់លោកនៅរស់ គាត់ទទួលបន្ទុក១០៥នៅឡើយ គាត់បានទៅជាមួយឪពុករបស់លោក ទៅ<មន្ទីរ>ក-១៧ ហើយគាត់បានឃើញ<ទាហានកងពលត្រូវបាន>គេដាក់<ឃុំឃាំង និង>ដាក់ខ្នោះជើងនៅ<ជាន់ខាងលើ>។ <ខ្ញុំសូមអានជូនលោកស្ដាប់ នូវអ្វីដែល> ណេត សាវ៉ាត <បាននិយាយ នៅពេលដែលគាត់មកបង្ហាញខ្លួននៅទីនេះ> គឺ<ប្រតិចារឹក> E1/400.1 នៅម៉ោង<១០:៥៩:០៧> ដកស្រង់៖ "សួរ៖ តើនៅពេលណាដែលលោកបានឃើញខ្នោះជើង<នោះ? តើវា>នៅក្នុង<អំឡុង>ខែ នៅពេលដែលលោកនៅក-១៧ ឬក្រោយមកដែលលោកបានឃើញខ្នោះជើងនេះ? ឆ្លើយ៖ គឺមុនពេលនោះ គឺមួយខែមុនពេលនោះ"។ បន្ទាប់មកទៀត "តាហម យកខ្ញុំទៅជាន់លើ <ពីព្រោះ>នៅពេលនោះ <>មនុស្សដែលមកពី -- <ដូចជា> តាសាន ជាប្រធានកងពល ត្រូវបានគេដាក់<នៅទីនោះជាមួយនឹងអ្នកផ្សេងទៀតមកពីកងពល។ នៅពេលគាត់នាំខ្ញុំទៅជាន់ខាងលើ ខ្ញុំបានឃើញពួកគេត្រូវបានដាក់>ខ្នោះជើង។" បញ្ចប់សេចក្ដីដកស្រង់<>។ តើឃ្លានេះបានរំឭកលោកឲ្យចងចាំអំពី<ការឃើញ>ទាហានកងពល ហើយនិង<អ្នកទោស>ផ្សេងៗទៀត <ត្រូវបាន>គេឃុំខ្លួន<នៅជាន់ខាងលើនៃ>មន្ទីរក-១៧ <>ដែរឬទេ លោកសាក្សី?

**ឆ៖** ខ្ញុំចាំអត់បានផង។ អត់ៗដែលឃើញគេឃុំខ្លួន អត់ដឹងទេ កាលជំនាន់ខ្ញុំនៅ ព្រោះនៅហ្នឹង កាលជំនាន់ខ្ញុំនៅ មានតែមករៀនសូត្រធម្មតាទេ។ សូមបញ្ជាក់ប៉ុណ្ណឹង បាទ។

[១០:០២:៥២]

**ស៖** តើលោកមានបានឃើញកងទ័ព កងពល៩២០ ជាច្រើនត្រូវបានគេចាប់ខ្លួនដែរទេ ពេលលោកធ្វើការនៅមន្ទីរតំបន់១០៥?

**ឆ៖** បញ្ជាក់ម្ដងទៀត ស្ដាប់អត់បានច្បាស់។

**ស៖** តើលោកនៅនឹកឃើញថា មានពេលមួយនៅពេលលោកនៅតំបន់១០៥ គឺគេបានចាប់ខ្លួនកម្មាភិបាលកងពល៩២០ជាច្រើន។ លោកនឹកឃើញទេ?

**ឆ៖** មកចាប់នៅមន្ទីរក-១៧ហ្នឹង កាលជំនាន់ខ្ញុំនៅអត់ៗមានទេបាទ មានតែរៀនសូត្រ ហើយគេជិះឡានឡើងឡានទៅបាត់។ គេថាមកក្រោមៗ មករៀនសូត្របន្តអីទៀតហ្នឹង អត់ដឹងដែរ បាទ អត់ដឹងថាគេចាប់ដែរ។

**ស៖** ខ្ញុំបញ្ជាក់សំណួរខ្ញុំឡើងវិញ។ ខ្ញុំសួរលោកថា តើលោកមានបានដឹងជាទូទៅនៅក្នុងអំឡុងពេលមួយដែលថា មានគេចាប់ខ្លួនកម្មាភិបាលកងពល៩២០ដែរទេ មិនមែនចាប់ខ្លួននៅក្នុងមន្ទីរក-១៧ទេ គឺចាប់ខ្លួនកម្មាភិបាលកងពល៩២០ <នៅក្នុងតំបន់១០៥>។ លោកដឹងមានដឹងទេ?

**ឆ៖** ដឹងថាចាប់ ប៉ុន្តែចាប់មកដាក់ក-១៧ កាលជំនាន់ខ្ញុំនៅ អត់មានទេ មានតែកាលជំនាន់ហ្នឹងមានចាប់ខ្លះ ប៉ុន្តែមិនមែនៗចាប់យកមកក-១៧ទេ។ គេបន្តពីនោះមក បានៗៗដឹងគេប្រកាសៗជាទូទៅ គេថាលោកនេះក្បត់ អ្នកនោះក្បត់អីអ៊ីចឹងទៅ អាហ្នឹងដឹងទូទៅ អាហ្នឹងមិនមែនៗដឹងតែម្នាក់ទេ បាទ។

[១០:០៥:០៧]

**ស៖** ខ្ញុំសូមអានឯកសារមួយ។ នេះគឺឯកសារ E3/877។ លោកសាក្សី នេះគឺជាសារទូរលេខដែលបញ្ជូនមកមន្ទីរ៨៧០នៅថ្ងៃទី២០ ឧសភា ៧៧ ដែលឪពុករបស់លោកជាអ្នកផ្ញើមក។ <លោកអាចនៅចាំឯកសារនេះ ដោយសារគេបានបង្ហាញលោក ហើយសួរលោកនូវសំណួរមួយចំនួនអំពីឯកសារនេះ>នៅពេលដែលលោកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ<នេះកាលពីលើកមុន>។ កថាខណ្ឌទី៣<នៃ>សារទូរលេខរបស់ឪពុកលោកនេះគឺសរសេរដូចតទៅ សូមដកស្រង់៖ “នៅថ្ងៃទី១៣ ឧសភា ៧៧ អង្គភាពតំបន់បាន<ស្លាប់ម្នាក់ និងម្នាក់ទៀត>ទទួលរបួសយ៉ាងធ្ងន់នៅពេលដែលខ្មាំងបានវាយសម្រុកចូលមក<នៅជិត>មន្ទីរ<តួជួយ ខាងត្បូងស្រា។ វា>មាន<>ចម្ងាយ<៥០>ម៉ែត្រពីមន្ទីរ។ <តាមការវាយតម្លៃរបស់យើងគឺថា នេះមិនមែនជាសត្រូវពីខាងក្រៅទេ។> យើងសង្ស័យថាពួកបក្សពួកអាសោម <> និងពួកបក្សពួកអាឈិន។ បញ្ហានេះបានរាយការណ៍ទៅឲ្យសមមិត្តសានហើយ ក្រៅពីការចាប់ខ្លួនកម្មាភិបាលកងពល៩២០ សកម្មភាពនេះក៏នៅតែបន្តជាហូរហែអ៊ីចឹង យើងក៏បានចាប់ខ្លួនជាបន្តបន្ទាប់។” បញ្ចប់ការដកស្រង់។ លោកសាក្សី នៅពេលដែលលោកផ្ដល់សក្ខីកម្ម<លើក>មុន លោកថាឈិននៅក្នុងសារទូរលេខនេះ ជាលេខាកងពល៩២០។ ខ្ញុំសូមសួរលោក ដំបូង តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថាតើមន្ទីរ<តួជួយ>ដែល<>និយាយនៅក្នុងសារទូរលេខនេះ<ជាអ្វី>? ហើយ<>មានទីតាំងនៅត្រង់កន្លែងណា<>?

**ឆ៖** សួយ ហ្នឹងជាមន្ត្រីយោធាម្នាក់ អាហ្នឹងចាំឈ្មោះគាត់បាន ប៉ុន្តែមន្ទីរគាត់នៅឯណា ខ្ញុំភ្លេចៗកន្លែងហើយ តែមានឈ្មោះ សួយ ហ្នឹងមែន។ កាលជំនាន់ហ្នឹងគាត់ដូចជាប្រធានវរសេនាតូចរបស់តំបន់ ប៉ុន្តែនៅត្រង់ណាចាំអត់ៗបានទេ ឥឡូវនេះបាទ។

[១០:០៧:៤២]

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកចាំថាអង្គភាពនេះមានតួនាទីធ្វើអ្វីដែរ?

**ឆ៖** អង្គភាពនេះកាលៗជំនាន់ហ្នឹងគេៗនៅព្រំដែនឯណោះទេបាទ គេភាគច្រើនបញ្ជូនមកព្រំដែនវៀតណាម។

**ស៖** ក្រោយពីស្ដាប់សារទូរលេខនេះហើយនេះ តើលោកចាំពីអំឡុងពេលឆ្នាំ៧៧ ដែលតំបន់ធ្វើការចាប់ខ្លួនកងទ័ពកងពល៩២០ជាច្រើននាក់ លោកនៅចាំទេ?

**ឆ៖** ចាំអត់បានទេបាទ ចាំ -- ដឹងតែថាបាត់អ្នកនេះ បាត់អ្នកនោះ គេប្រកាសជាផ្លូវការ បើថាឲ្យចាំថា ឃើញចាប់អ្នកនេះអ្នកនោះនៅនឹងកន្លែងនោះ អត់ៗៗមានទេ បាទ អត់បានឃើញទេ។ ដឹងថាមានចាប់។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកនិយាយឈ្មោះបុគ្គលជាក់លាក់នេះមួយ តើលោកនិយាយសំដៅទៅដល់<យ៉ាងហោចណាស់ផ្នែកនៃ>កងទ័ពកងពល៩២០<>ឬក៏និយាយ<>ពីបុគ្គលជាទូទៅ<>?

**ឆ៖** ជាទូទៅ។

**ស៖** ទាក់ទងទៅនឹង<>សេចក្ដីរាយការណ៍របស់ឪពុកលោកនៅក្នុងសារទូរលេខហ្នឹងថា <"យោងទៅតាម>ការចាប់<ខ្លួនអង្គភាព៩២០ ការ>ធ្វើសកម្មភាព<នានា>បន្ត<ធ្វើជាហូរហែ ប៉ុន្តែយើងបានធ្វើការចាប់ខ្លួនជាបន្តបន្ទាប់ផងដែរ"។> តើលោកដឹង<ទេ>ថាឪពុករបស់លោកបានធ្វើសេចក្ដីសម្រេច <ដោយខ្លួនគាត់> ថាអ្នកណាត្រូវចាប់ខ្លួន <ឬក៏>គាត់ទទួលបានសេចក្ដីណែនាំណា<ពីអ្នកផ្សេង>?

**ឆ៖** អត់បានដឹងទេបាទ។

**ស៖** តើកងពល៩២០ មានមន្ទីរសន្តិសុខផ្ទាល់ខ្លួននៅមណ្ឌលគិរីនោះដែរឬទេ? ឬក៏<គេប្រើប្រាស់មន្ទីរសន្តិសុខតំបន់?>

**ឆ៖** ខ្ញុំអត់ដឹងដែរបាទ។

[១០:១១:០៣]

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ ម៉ោង -- ពីពេលនេះទៅរហូតម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយលោក ញ៉ែម សំណាង *(ស៊ីក)* ហើយនិងលោកសាក្សី ឥឡូវនេះយើងសម្រាក ហើយ

រហូតដល់ម៉ោងដប់កន្លះយើងបន្តកិច្ចដំណើរការសវនាការរបស់យើងទៀត។ ដូច្នេះ លោកទាំងពីរនាក់ឲ្យមានវត្តមាននៅកន្លែងដែលផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នុំងគឺឲ្យបានមុនពេលម៉ោងដប់កន្លះ។ លោកយល់ទេ?

**លោក ជួង សុភារិទ្ធ៖**

បាទ យល់បាទ។ ស្តាប់បានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោកសាក្សី តើលោកបានត្រៀមខ្លួនរួចរាល់ហើយឬនៅ?

**លោក ផាន វ៉ាន៖**

រួចរាល់ហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី ប៉ុន្មានឆ្នាំមុននេះ ពេលលោកមកផ្តល់សក្ខីកម្ម លោកបានលើកឡើងថា ឈិនគឺជាមេកងពល៩២០ ហើយ តាសាន ក៏បានឡើងជំនួស តាឈិន ជាលេខាកងពលនេះ។ ឥឡូវនេះ ខ្ញុំ

សូមសួរលោក បុគ្គលម្នាក់ទៀតឈ្មោះ តាសែ។ តើលោកដឹងថា តាសែ នេះ<ជាអ្នកណាទេទាក់ទងទៅ>នឹងកងពល៩២០ <នោះ>?

[១០:៣៣:០៨]

**លោក ផាន វ៉ាន៖**

**ផ៖** តាសែ ខ្ញុំអត់ៗស្គាល់ផង អត់ដែលឮឈ្មោះទេ។

**ស៖** អនុញ្ញាតឲ្យខ្ញុំអានឈ្មោះនេះឡើងវិញ។ លោកស្គាល់មនុស្សម្នាក់ឈ្មោះ តាសយ លោកស្គាល់ទេ ពាក់ព័ន្ធទៅនឹងកងពល៩២០ នេះ?

**ផ៖** តាសយ ស្គាល់ តាសយ គាត់រង តាឈិន បាទ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ មានអ្វីកើតឡើងចំពោះ តាឈិន ហើយនិង <> ហើយនិង តាសយ នេះនៅក្នុងឆ្នាំ១៩៧៧?

[១០:៣៤:១៤]

**ប្រធានអង្គជំនុំ៖**

ម្តងទៀត ចេញឈ្មោះ ជឹម មកអីទៀតហើយ អំមិញនិយាយរឿងឈ្មោះ ឈិន សោះ ឥឡូវស្រាប់ដល់ពេលសំណួរទី២ ដល់ចេញៗឈ្មោះ ជិន អីណាមក។ អ្នកឆ្លើយៗមិនរួចទេ។

**លោក ស្រ៊ា រតនៈ៖**

សូមៗការអនុញ្ញាតពីលោកប្រធាន តាមពិតគាត់អានថា តាឈិន ទេ មិនមែន តាជឹម ទេ។ តាឈិន ប៉ុន្តែអ្នកបកប្រែគាត់ៗស្តាប់ច្រឡំបាទ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិ តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត ហើយឲ្យមានការបកប្រែត្រឹមត្រូវ។ អ៊ីចឹងអ្នកឆ្លើយៗមិនរួចទេ អត់មានចេញឈ្មោះ ជិន ហ្នឹងមកពីណាផងឥឡូវស្រាប់ចេញឈ្មោះផ្សេង ហើយឈ្មោះដើម សួរសំណួរដំបូងឈ្មោះផ្សេងអ៊ីចឹងនុះ។

**សួរដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** បាទ ខ្ញុំនឹងសួរឡើងវិញ។ លោកសាក្សី ខ្ញុំសួរលោកថា តើលោកអាចជម្រាបជូនតុលាការ<បានទេ>ថា មានអ្វីកើតឡើងដល់ តាឈិន និង តាសយ ក្នុងឆ្នាំ៧៧?

**លោក ផាន វ៉ាន់៖**

**ផ៖** ខ្ញុំអត់ដឹងទេបាទ អ្វីដែលកើតឡើង ក្រោយមកដឹងតែថា គេប្រកាសថាក្បត់ តែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំសូមអានចម្លើយមួយរបស់លោក ដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺ E3/58, ERN ជាភាសាអង់គ្លេស <00250088> ដល់ 89, ខ្មែរ <00239936> និងបារាំង <00283914>។ នេះគឺជាអ្វីដែលលោកបានឆ្លើយ "នៅថ្ងៃមួយ ប្រហែលជាចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧ តាឈិន បានទូរស័ព្ទមកឪពុកខ្ញុំប្រាប់ថា សេនាធិការបានហៅគាត់ទៅប្រជុំ។ ខ្ញុំឮឪពុកខ្ញុំនិយាយយ៉ាងដូច្នេះ។" បញ្ចប់ការដក ស្រង់។ ហើយលោកបានបន្តរៀបរាប់ពីរបីចំណុចទៀត សូមដកស្រង់៖ "មុនពេលការចាប់ តាឈិន និងតាសយ និងក្រោយពី តាឈិន និង តាសយ ស្លាប់ទៅ។" បញ្ចប់ការដកស្រង់។ តើចំណុចនេះ រំឭកដល់ការចងចាំរបស់លោកទេ ដែល តាឈិន និង តាសយ ត្រូវបានចាប់ខ្លួន និងសម្លាប់នៅក្នុងឆ្នាំ១៩៧៧?

**ផ៖** អត់យល់ន័យដែលសួរ បាទ ព្រោះខ្ញុំអត្ថាធិប្បាយអ៊ីចេះ កាលជំនាន់ហ្នឹង គេហៅមកធ្វើ ដឹងថាគេហៅមកធ្វើ មកបាត់ ហើយស្លាប់។ សម្លាប់ពីអង្កាល់អីអង្កាល់ អត់បានដឹងទេ ប៉ុន្តែកាលពីហ្នឹងមុន គេប្រកាសថា ក្បត់ អ៊ីចឹងទៅ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** លោក<ចាំ>ទេថា អ្នកណាហៅពួកគាត់ឱ្យមកធ្វើការហ្នឹង?

**ផ៖** កាលជំនាន់ហ្នឹង ដឹងតែថា ខាងលើៗ អ៊ីចឹង មិនដឹងអ្នកណាខ្លះ បាទ។

**ស៖** ពេលលោកនិយាយថា ថ្នាក់លើហ្នឹង តើលោកយោងទៅលើបុគ្គលអ្នកណាម្នាក់នៅភ្នំពេញ ឬក៏យោងទៅលើអ្វី?

**ផ៖** យោងទៅលើអ្នកនៅភ្នំពេញ ព្រោះគេហៅមកភ្នំពេញ។

**ស៖** លោកចាំខែដែល តាឈិន និង តាសយ ត្រូវបានគេហៅមកឱ្យធ្វើការនៅភ្នំពេញនេះដែរទេ?

[១០:៣៨:៤១]

**ផ៖** អត់ចាំទេ បាទ ចាំអត់បានទេ។

**ស៖** លោកសាក្សី នៅក្នុងសំណុំរឿង យើងមានបញ្ជីអ្នកទោស ស-២១ ឯកសារE3/342 ដែលបញ្ជាក់ថា លេខាកងពល៩២០ ម៉ែន ម៉េង ហៅ ឈិន ហ្នឹង បានចូលមកស-២១ នៅថ្ងៃ១៦ មីនា ៧៧? គឺលោកប្រធាន គឺលេខរៀង ៥១១៨។ លេខា<រង>កងពល<នោះឈ្មោះ អ៊ា ជឺ ហៅ> សយ <>បានចូលមកនៅ ស-២១ គឺថ្ងៃ១៧ កុម្ភៈ ៧៧ <លេខ ១៩៦៦>។ តើចំណុចនេះ ជួយរំឭកដល់ការចងចាំ

របស់លោកទេ ថានៅម៉្តុំខែកុម្ភៈ ឬមីនា នេះ ឈិន និង សយ ត្រូវបានគេហៅមកភ្នំពេញ?

**ឆ៖** បានដឹង ដែលដឹងថាមកភ្នំពេញ បើតែចាំខែឆ្នាំ ចាំអត់បានទេបាទ។

**ស៖** ចុះលោកដឹងថាមានអ្វីកើតឡើងទៅដល់ប្រពន្ធ តាឈិន និង តាសយ ដែរទេ ក្រោយអ្នកទាំងពីរហ្នឹងត្រូវបានគេ<>បញ្ជូនមកភ្នំពេញនេះ?

**ឆ៖** ដឹងតែក្រោយពេលគេបញ្ចោប្រកាស បាន១ដឹង។ គេប្រកាសជាទូទៅ ថាក្បត់អ៊ីចឹង។

**ស៖** សូមសួរបញ្ជាក់<ឲ្យច្បាស់ នៅពេលលោកនិយាយថា> ពួកគេត្រូវបានចោទប្រកាន់ថាក្បត់ <តើ>លោកសំដៅ<ទៅលើ>ប្រពន្ធ តាឈិន តាសយ ឬ<>?

**ឆ៖** ថាម៉េចបាទ? ស្តាប់អត់១បាន។

**ស៖** ខ្ញុំសួរលោកថា តើលោកដឹងថា មានអ្វីកើតឡើងចំពោះប្រពន្ធតាឈិន និងប្រពន្ធតាសយ ក្រោយពី តាឈិន និង តាសយ នេះ ត្រូវបានគេបញ្ជូនមកភ្នំពេញ?

**ឆ៖** ក្រោយមកដឹង១ថាគេយកកូន យកប្រពន្ធយកអីទៅទាំងអស់ ជំនាន់ហ្នឹងមិនមែនចំពោះតែតាឈិន, តាសយ ទេ អ្នកផ្សេងហ្នឹង បើថា១គេប្រកាសថាក្បត់ហើយ កូនប្រពន្ធគេយកទៅទាំងអស់។

[១០:៤១:៥៥]

**ស៖** ខ្ញុំសូមសួរលោកដោយស្រង់សម្រង់ពីរ ពីចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ទី១ គឺ E3/58, ERN ជាភាសាអង់គ្លេស 00250092, ខ្មែរ 00239940, បារាំង 00283918។ លោកសាក្សី លោកបានឆ្លើយអំពីការពិភាក្សាមួយដែលឪពុករបស់លោកបានពិភាក្សាជាមួយលេខភូមិភាគ<ឦសាន>គឺ តាយ៉ា ហើយនិងជាមួយ តាឈិន ហើយនិង តាសយ។ សូមដកស្រង់៖ "ថ្ងៃមួយនៅពេលខ្ញុំរៀបចំអាហារឲ្យឪពុករបស់ខ្ញុំ <គាត់បាន>ពិភាក្សាជាមួយ តាយ៉ា។ ខ្ញុំ<អាចស្តាប់>ឮសួរការពិភាក្សានោះ។ នៅក្នុងការពិភាក្សានោះគឺថា <ឪពុកខ្ញុំបានស្នើសុំឲ្យ> តាយ៉ា <>និយាយជា<មួយ> អង្គការ ចំពោះការចរចាជាមួយវៀតណាម កុំ<ឲ្យ>ប្រយុទ្ធជាមួយវៀតណាម អី។ ការលើកឡើងនេះតាឈិន, តាសយ និង តាវែង ក៏មានវត្តមានហើយក៏យល់ស្របចំពោះការលើកឡើងនេះដែរ។" បញ្ចប់ការដកស្រង់។ លោកសាក្សីហើយបន្ទាប់មកលោកឆ្លើយទៀត គឺE3/57, ERN អង់គ្លេស 00290507, ខ្មែរ 00287704, បារាំង 00353103។ លោកបានឆ្លើយដូចតទៅ៖ "នៅថ្ងៃមួយនៅពេលបាយល្ងាចឪពុកខ្ញុំនិយាយជាតាយ៉ា តាសយ តាវែង និងតាឈិន អំពីការលុបបំបាត់លុយកាក់ និងការវាយប្រហារពីវៀតណាមចូលមកតំបន់<ទុយោសាំង> នៅពេលនោះឪពុករបស់ខ្ញុំលើកឡើងថា តាយ៉ា នឹងធ្វើការ

ជំទាស់តវ៉ាក្នុងពេលប្រជុំសភានោះ ដោយសារថាគាត់គឺជាថ្នាក់ដឹកនាំជាន់ខ្ពស់។ ក្រោយគេប្រជុំហ្នឹង តាយ៉ា តាវ៉ែង តាឈិន <> ក៏បានបាត់ខ្លួន។" បញ្ចប់ការដកស្រង់។

លោកសាក្សីលោកដឹងទេថា ហេតុអ្វីបានជាឪពុករបស់លោក ពេញចិត្តនឹងការចរចាជាមួយវៀតណាមជាជាងការប្រឈមមុខប្រដាប់អាវុធទៅវិញនោះ?

[១០:៤៤:៣៤]

**ឆ៖** កាលជំនាន់ហ្នឹងមានៗនិយាយមែន បាទ កាលជំនាន់ហ្នឹងវៀតណាមវ៉ៃ -- ឲ្យវ៉ៃយកទុយោសាំង បើខ្ញុំចាំណ៌ា អាកន្លែងទុយោសាំងនៅសែនមនោរម្យ នៅជាប់ព្រំប្រទល់។ តែហ្នឹង ខ្ញុំចាំអត់ច្បាស់ទេ មិនដឹងនៅៗត្រង់ណាទុយោសាំងហ្នឹង គ្រាន់តែថា គេហៅទុយោសាំង នៅមួយជួរដាក់ដាំហ្នឹងឯង ព្រោះកាលហ្នឹងគេឲ្យវ៉ៃយកទុយោសាំងហ្នឹង ដល់អ៊ីចឹង វាវ៉ៃទៅវាប៉ះពាល់។ ហើយអ៊ីចឹងខាងឪពុកខ្ញុំហ្នឹង គាត់និយាយជាមួយ តាយ៉ា អីទៅ មកវ៉ៃហើយ ឲ្យនិយាយពីខាងលើកុំឲ្យវ៉ៃ កុំចង់វ៉ៃគ្នាអ៊ីចឹង។ ហើយទៅធ្វើការចេញមកហ្នឹង ដូចមកតែឪពុកខ្ញុំមកស្រុកវិញមកបាត់ ហើយគាត់នៅ ថានៅរៀនសូត្របន្ត ដឹងតែប៉ុណ្ណឹងទេ ដំបូង។

**ស៖** ហើយនៅក្នុងអង្គប្រជុំនេះ ដែលលោកបានលើកឡើងមកនិយាយថា លេខាភូមិភាគព្លសានហ្នឹង គឺអាចនឹងស្នើសុំឲ្យអង្គការចរចាជាមួយវៀតណាមវិញ កុំវាយប្រយុទ្ធជាមួយវៀតណាមអី។ អ៊ីចឹងថា តើការប្រជុំនេះប្រជុំនៅកន្លែងណា? ហើយនៅពេលណាដែរ?

**ឆ៖** ចាំពេលអត់បាន ប្រជុំ ប្រជុំនៅជាមួយលេខាហ្នឹងនៅខេត្តមណ្ឌលគិរីហ្នឹង នៅខេត្តបច្ចុប្បន្ននេះបាទ។

**ស៖** បាទ សូមបញ្ជាក់ឲ្យបានច្បាស់ តើលោកដឹងអំពីអង្គប្រជុំមួយទៀត នៅពេលដែលលេខាឈ្មោះ យ៉ា នេះអាចបញ្ជូន<សំណូមពររបស់គាត់>ឲ្យមេៗរបស់គាត់ទេ?

**ឆ៖** មិនបានដឹងទេបាទ មិនដឹងគាត់លើកឡើងឬក៏យ៉ាងណា អត់ដឹងទេបាទ។

[១០:៤៧:០២]

**ស៖** អង្គប្រជុំដែល<លោកបានបញ្ជាក់>ប្រារព្ធធ្វើឡើងនៅមណ្ឌលគិរី ដែលមាន តាយ៉ា <ជាលេខា>ចូលរួមដែរហ្នឹង លោកនឹកឃើញទេ<តើ>ប្រជុំនៅ<ពេល>ណាដែរ?

**ឆ៖** នៅទីរួមខេត្តមណ្ឌលគិរី។

**ស៖** ចុះលោកនៅនឹកឃើញពេលវេលាទេ? នៅខែណា ឆ្នាំណាដែរ?

**ឆ៖** ចាំខែឆ្នាំអត់បានទេអាហ្នឹង។

**ស៖** <>ម៉េចបានលោកដឹងថាមានអង្គប្រជុំហ្នឹងធ្វើឡើង?

**ឆ៖** ពីព្រោះនឹកឃើញកាលជំនាន់ហ្នឹងទៅប្រជុំ គេទៅត្រួតមើលសមរភូមិនៅខេត្តមណ្ឌលគិរី ។

**ស៖** <តើ>អ្នកណា<ជាពួកគេហ្នឹង> ដែលទទួល<>បន្ទុកសមរភូមិនៅ<ខេត្ត>នុ៎ង?

**ឆ៖** កាលជំនាន់ហ្នឹង អ្នកទទួលសមរភូមិ តាឈិន ហើយខាងតំបន់ហ្នឹងគឺឈ្មោះ រៀង អាហ្នឹង អ្នកទទួលសមរភូមិផ្ទាល់។

**ស៖** លោកសាក្សី តើលោកដឹងថា គេមានបញ្ជូនចម្លើយសារភាពពីភ្នំពេញទៅតំបន់១០៥ ដោយមានឈ្មោះអ្នកទាំងឡាយដែលត្រូវបានជាប់ពាក់ព័ន្ធ ហើយដែលនឹងត្រូវចាប់ខ្លួន លោកដឹងថាមានគេធ្វើអ៊ីចឹងទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** ចុះលោកដែលដឹងថាមាននីរសារណាបញ្ជូនឯកសារនេះពីភ្នំពេញទៅមន្ទីរក-១៧នោះដែរទេ?

**ឆ៖** អត់យល់ឯកសារអី ។

**ស៖** តើលោកធ្លាប់ឃើញនីរសារណាម្នាក់បញ្ជូនឯកសារចេញពីភ្នំពេញ បញ្ជូនទៅឱ្យមន្ទីរក-១៧ នោះដែរទេ?

**ឆ៖** ឯកសារអី អត់ៗអត់យល់ពីឯកសារ។

**ស៖** បាទ នៅត្រង់ចំណុចនេះ ខ្ញុំសួរជារួមតែម្តង ថាតើលោកមានដែលដឹងថា មាននីរសារណាទៅដល់មន្ទីរ ក-១៧ ដោយយកឯកសារចេញពីភ្នំពេញ យកទៅឱ្យមន្ទីរ ក-១៧ ទោះជាឯកសារអ្វីក៏បានដែរ?

**ឆ៖** អត់បានដឹងទេ បាទ។

[១០:៥០:៥៨]

**ស៖** ខ្ញុំសូមអានសម្រង់មួយឆ្លើយជូនមន្ត្រីស៊ើបអង្កេត គឺកិច្ចសម្ភាសន៍<ជាមួយហាំ អនស៊ី> E3/366, ERN ជាភាសាអង់គ្លេស 00250750, ខ្មែរ 00242413 ដល់ 14, បារាំង 00283165 ដល់ 66។ នេះអ្វីដែល ហាំ អនស៊ី គាត់បានឆ្លើយ៖ "ខ្ញុំដឹងថា តាសាន <អតីតអនុកងពល៨០១របស់សារឿន បានមកជំនួស ឈិន។> នៅកែវសីមា ខ្ញុំឃើញ តាសាន ចាប់កងទ័ពកងពល៩២០ ជាច្រើន ហើយ

បញ្ជូនមកមជ្ឈិម។ តាសុភា ឲ្យខ្ញុំអានចម្លើយសារភាព<មកពីមជ្ឈិម>ដែលកងទ័ព កងពល៩២០ ឆ្លើយដាក់កងទ័ពដទៃទៀត។ ខ្ញុំមិន<ចាំ>ឈ្មោះអ្នកឆ្លើយសារភាពទេ។ ខ្ញុំចាំមនុស្សម្នាក់ ដែលត្រូវគេឆ្លើយដាក់ហ្នឹង គឺប្រធាន<អនុសេនាធំ>នៅ<ស្រុក>កែវសីមា។” បញ្ចប់ការដកស្រង់។

លោកសាក្សី តើចំណុចនេះរំឭកដល់ការចងចាំរបស់លោក<ដែរទេ> ដែលលោកបានអាន ឬក៏បានឃើញចម្លើយសារភាពដែលគេផ្ញើពីភ្នំពេញ ទៅតំបន់១០៥?

**ឆ៖** ខ្ញុំអត់បានដឹងទេ បាទ រឿងៗហ្នឹង។

**ស៖** លោកសាក្សី លោកអាចជម្រាបជូនតុលាការបានទេ តើ<>ឈ្មោះ ហាំ អនស៊ី នេះ ជាអ្នកណាដែរទេ?

**ឆ៖** ដូចមិន មិនមានឈ្មោះ ហម ហាន់ នុ៎ងទេ បាទ។

**លោក ស្រ៊ា រតនៈ៖**

សូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមបញ្ជាក់ថា បុគ្គលនោះ គឺឈ្មោះ ហាំ អនស៊ី។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** បាទ ដោយមានការជួយសម្រួលពីសហការីរបស់យើងខ្ញុំ តើលោកស្គាល់បុគ្គលម្នាក់នេះទេ លោកអាចជម្រាបជូនតុលាការបានទេ?

[១០:៥៣:៣៥]

**លោក ខាំ ផាន់៖**

**ឆ៖** ស្តាប់ឈ្មោះ អត់ៗច្បាស់អំមិញ។ ហម ហាន់ វាអត់ៗមានដែលឮទេ។ ហម ហាន់ ខាំផន អត់ដែលមានឮឈ្មោះ។

**លោក ស្រ៊ា រតនៈ៖**

លោកសាក្សី ឈ្មោះដែលលោកសហព្រះរាជអាជ្ញារងអន្តរជាតិគាត់បានជម្រាបសួរហ្នឹង គឺឈ្មោះ ហាំ អនស៊ី។

**លោក ផាន វ៉ាន៖**

**ឆ៖** ហាំ អនស៊ី ព្រោះហៅតែៗជំនាន់ហ្នឹង ហៅឈ្មោះ អនស៊ី។ អនស៊ី ចៅហ្វាយស្រុក។ កាលនោះ ឋានៈគេហៅគណៈស្រុកកែវសីមា។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** តើគាត់មានជាប់សាច់ញាតិអ្វីជាមួយនឹងលោកទេ?

**ឆ៖** អនស៊ី ហ្នឹងសាច់ -- សាច់ញាតិខាងឪពុកខ្ញុំ ប្អូនឪពុកខ្ញុំបង្កើត។

**ស៖** លោកសាក្សី តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា <តើលោកដឹងថា>ប្រជាជនប្រភេទណាដែលត្រូវបញ្ជូនទៅមន្ទីរសន្តិសុខទំនប់ភ្នំក្រោលនោះ នៅពេលដែលគេចាប់ខ្លួន?

**ឆ៖** ខ្ញុំមិនដឹងទេបាទ ដឹង។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកមួយគឺឯកសារ E3/58, ERN ជាភាសាអង់គ្លេស 0025 0088, ខ្មែរ 00239936, បារាំង 00283914។ សូមដកស្រង់៖ “អ្នកដែលគេយកមកអប់រំកែប្រែនៅមន្ទីរសន្តិសុខទំនប់ភ្នំក្រោល គឺមានអ្នកដែលប្រព្រឹត្តខុសសីលធម៌ <ខុសវិន័យ> លួច ប្លន់ <និងគេចពីការងារ>។ នៅក្នុងករណីនីមួយៗ អ្នកទោសហ្នឹងគឺត្រូវរៀបចំប្រវត្តិរូបរបស់ខ្លួន។” បញ្ចប់ការដកស្រង់។ លោកសាក្សី តើចំណុចនេះរំឭកដល់ការចងចាំរបស់លោកថា មនុស្សប្រភេទនេះ គឺដូចជាអ្នកបានប្រព្រឹត្តខុសសីលធម៌ មានដៃមានជើង លួចឆក់អីនេះជាដើម គឺត្រូវគេ<ចាប់ខ្លួន និងឃុំខ្លួននៅ> មន្ទីរសន្តិសុខទំនប់ភ្នំក្រោល លោកដឹងទេ?

**ឆ៖** កាលជំនាន់ហ្នឹងមានមែនបាទ។

**ស៖** លោកក៏បានឆ្លើយនៅក្នុងសក្ខីកម្មលើកមុនរបស់លោកចំពោះអង្គជំនុំជម្រះ គឺ E1/152.1 នៅម៉ោង០៩:៥៦:១១៖ “នៅក្នុងសម័យនោះ ដូចខ្ញុំបានឆ្លើយខាងដើមហើយគឺថាអ្នកដែលមិនគោរពវិន័យ គឺថាត្រូវការជាខ្មាំងដែលអសកម្ម ហើយអ្នកដែលមានប្រវត្តិជាគ្រូ ឬជាមន្ត្រីរបបចាស់ គឺជាគោលដៅនៃការវែកមុខចាប់ខ្លួននេះហើយ។” លោកសាក្សី តើលោកអាចជម្រាបជូនតុលាការថា<តើអ្នកណាជាអ្នកសម្រេចថា> អំពើបែបណាដែលគេចាត់ទុកថាជាអំពើខុសសីលធម៌នោះនៅក្នុងតំបន់១០៥ ឬក៏មន្ត្រីរបបចាស់<ដែល>ត្រូវតែដកចេញនោះ?

**ឆ៖** អត់យល់អត្ថន័យបាទ។

[១០:៥៧:៣៥]

**ស៖** តើវាជាសេចក្ដីសម្រេចរបស់ឪពុកលោកក្នុងឋានៈជាលេខាតំបន់១០៥ ដែលសម្រេចទៅលើថាអ្នកណាជាអ្នកប្រព្រឹត្តខុសសីលធម៌ ឬអ្នកណាដែល<ជាមន្ត្រី>របបចាស់<>ត្រូវតែដក<ចេញ> ឬក៏គាត់ទទួលសេចក្ដីណែនាំពីអ្នកណាផ្សេង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អាហ្នឹងសូមបញ្ជាក់ ព្រោះអាហ្នឹងជាការណែនាំរបស់ៗខាងលើ ណែនាំមកឲ្យៗធ្វើតាមហ្នឹងបាទ។

**ស៖** នៅពេលដែលនិយាយថាសេចក្ដីសម្រេចហ្នឹងមកពី ថ្នាក់លើៗហ្នឹង តើលោកសំដៅទៅលើអ្នកណា?

**ឆ៖** ថ្នាក់លើហ្នឹងថ្នាក់លើកំពូលមកពីភ្នំពេញនោះ។

**ស៖** នៅពេលដែលលោកមកផ្ដល់សក្ខីកម្មលើកមុន លោកថាមានការប្រជុំនៅមន្ទីរក-១៧ ជាប្រចាំខែ។ តើឪពុករបស់លោកបញ្ជូនការណែនាំពីភ្នំពេញហ្នឹងទៅឲ្យអ្នកដទៃទៀតនៅក្នុងតំបន់១០៥ <ពាក់ព័ន្ធនឹង>អ្នក<>ត្រូវចាត់ទុកជាខ្មាំងនោះដែរទេ?

**ឆ៖** មតិណែនាំពីភ្នំពេញហ្នឹងបញ្ជូនឲ្យតាមលេខាស្រុកទាំងអស់ហ្នឹងឲ្យគេៗអានហ្នឹង មើលទាំងអស់ហ្នឹងបាទ ដែលត្រូវកំណត់ថាអ្នកណាជាអ្នកក្បត់អីៗហ្នឹង អត់ដឹងទេបាទ។

**ស៖** តើ<មានវិធីសាស្ត្រអីផ្សេងទៀតទេ>ក្រៅពីកិច្ចប្រជុំដែលឪពុករបស់លោក<អាច>ប្រាប់អំពីសេចក្ដីណែនាំពី<មជ្ឈិម>ទៅហ្នឹង តើមានកិច្ចប្រជុំណាផ្សេងទៀតដែរទេ?

**ឆ៖** ការប្រជុំនោះ វាមានៗច្រើនប្រភេទ មានផ្សព្វផ្សាយមតិណែនាំ ឬសារាចរពីខាងលើអីអ៊ីចឹងទៅ ហើយកិច្ចប្រជុំពិសោធការងារអីៗហ្នឹង វាច្រើនទៀតបាទ។ សូមបញ្ជាក់ប៉ុណ្ណឹង។

[១១:០០:៤៣]

**ស៖** តើថ្នាក់ដឹកនាំ<បក្ស>ណាម្នាក់នៅភ្នំពេញ ដែលផ្ដល់មតិណែនាំទៅឲ្យឪពុករបស់លោកពាក់ព័ន្ធទៅនឹង<បញ្ហា>សន្តិសុខនេះ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ ឃើញតែតាមសារទូរលេខណែនាំពីនេះពីនោះអ៊ីចឹងទៅ អត់ដឹងបុគ្គលណាទេបាទ។

**ស៖** ខ្ញុំសូមអានសម្រង់មួយ គឺឯកសារ E3/58 ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត អង់គ្លេស 00250089, ខ្មែរ 00239937, បារាំង 00283915។ លោកបានឆ្លើយថា សារទូរលេខ <ឬសេចក្ដីរាយការណ៍ដែលលោក>បញ្ជូន<ពី>ឪពុករបស់លោក<ទៅ គឺ>ពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខនេះ គឺបានផ្ញើមកឲ្យ នួន ជា ហៅ អ៊ំនួន។ <ហើយលោកបានផ្ដល់សក្ខីកម្មដូចខាងក្រោម អំពីការណែនាំដែលទទួលពីការឆ្លើយតប។> សូមដកស្រង់៖ "<>មុនការស្លាប់របស់ឪពុកខ្ញុំ នួន ជា តែងតែណែនាំជាហូរហែពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ដូចជា<ឲ្យប្រុងប្រយ័ត្នចំពោះខ្មាំងយួន និងខ្មាំងស៊ីរូងផ្ទៃក្នុង>

មហិច្ឆតារបស់វៀតណាម ហើយនិង<ការងារខាងមនោគមន៍វិជ្ជាសម្រាប់បង្រៀនដល់ថ្នាក់ស្រុក>។ បន្ថែមលើនោះទៀត នួន ជា បានផ្ញើសំបុត្រ<ទៅកម្រិត>តំបន់<ឲ្យ>មកប្រជុំនៅភ្នំពេញ” ហើយនៅពេលលោកចូលមកឆ្លើយជូនតុលាការលើកមុន គេបានសួរថា៖ “តើលោកមានដឹងថា នួន ជា មាន<ចេញសេចក្ដីណែនាំពី>បញ្ហាសន្តិសុខ <បញ្ហារក្សាការប្រុងប្រយ័ត្ន និងបញ្ហាវត្តមានរបស់សត្រូវនៅក្នុងសារទូរលេខទាំងអស់នោះ>ទេ?” លោកថា៖ “ខ្ញុំនឹកឃើញ<>ការណែនាំ<មួយចំនួន។ នៅពេលនោះ> មតិណែនាំ<ក៏មាននាទី>ជាការរំឭកទៅដល់កម្មាភិបាលទូទៅ<ផងដែរ>។ ជាការពិតហើយ គឺថាមានមតិណែនាំបែបនេះមែន”។ បញ្ចប់ការដកស្រង់។ លោកសាក្សី តើចំណុចនេះ រំឭកដល់ការចងចាំរបស់លោកទេថា <>លោក ឬក៏ថាមន្ទីររបស់<>របស់លោកហ្នឹង បានទទួលមតិណែនាំ<បែបនោះ>ពី នួន ជា?

[១១:០២:៥៩]

**ឆ៖** អាហ្នឹងមានមែនបាទ ខ្លឹមសារស្អីៗហ្នឹងវាច្រើនទៀត ចាំអត់អស់ទេ។ តែមានការណែនាំរហូតបាទ។

**ស៖** ហើយការណែនាំប្រភេទនេះ<ឬ> ដែលឪពុករបស់លោក<ត្រូវ>បញ្ជូនទៅកម្មាភិបាលតំបន់ផ្សេងៗទៀត<>?

**ឆ៖** បញ្ជូនបាទ។

**ស៖** នៅក្នុងសម័យដែលឪពុករបស់លោកធ្វើជាលេខតំបន់ តើគាត់ធ្វើដំណើរជាទៀងទាត់ទៅភ្នំពេញដែរឬទេ?

**ឆ៖** អត់ទៀងទេបាទ អត់ទៀងទាត់ទេ។ ទាល់តែគេហៅទៅ បានទៅ។

**ស៖** តើលោកអាចប៉ាន់ប្រមាណបានទេ ថាតើគេហៅគាត់ទៅភ្នំពេញញឹកញាប់ប៉ុនណា?

**ឆ៖** ចាំអត់បាន *(ឮមិនច្បាស់)*។

**ស៖** នៅពេលដែលគាត់ត្រឡប់មកពីប្រជុំនៅភ្នំពេញវិញ តើគាត់តែងតែផ្សាយការណែនាំដែលគាត់បានទទួលពីការប្រជុំនៅភ្នំពេញដែរឬទេ?

**ឆ៖** ពេលគាត់ត្រឡប់មកពីភ្នំពេញវិញ គាត់ហៅអ្នកពាក់ព័ន្ធ ឬក៏ខាងស្រុក ខាងអីហ្នឹងមករៀនសូត្រនៅមន្ទីរ ក-១៧។

[១១:០៤:៥៧]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំពិនិត្យឃើញថា ខ្ញុំបញ្ចប់ពេលវេលារបស់ខ្ញុំ ហើយខ្ញុំគិតថាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏មានពេលសំណួរដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីនាំមុខសូមអនុញ្ញាតប្រគល់សិទ្ធិនៅក្នុងការសួរសំណួរទៅសាក្សីទៅលោកស្រី មេធាវី ស៊ីន សុវ៉ន។ សូមលោកប្រធានអនុញ្ញាត។

[១១:០៥:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស ជាដំបូង -- ចាស សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម និងអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស សូមជម្រាបសួរលោកសាក្សី!

**លោក ផាន វ៉ាន៖**

**ផ៖** បាទ ជម្រាបសួរ។

**ស៖** ចាស ខ្ញុំឈ្មោះ ស៊ីន សុវ៉ន ជាមេធាវីនៅអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្តឹង។ ហើយខ្ញុំសូមសួរសំណួរលោកមួយចំនួន ហើយសំណួរដែលខ្ញុំសួរៗបន្តពីសហព្រះរាជអាជ្ញា។ យើងឃើញថាលោកបានឆ្លើយសំណួរច្រើនជាមួយសហព្រះរាជអាជ្ញាអស់ហើយ ក៏ប៉ុន្តែខ្ញុំចង់សួរលោកមួយចំនួនទៀត។ សូមលោកសហការជាមួយខាងខ្ញុំផងចាស។ ចាស សំណួរទី១ ខ្ញុំចង់ជម្រាបសួរលោកថា លោកចូលធ្វើការជាអ្នកបកប្រែឯកសារអង្គុលីលេខសម្ងាត់

ជាមួយឪពុកលោកហ្នឹង សូមលោកបញ្ជាក់ឲ្យច្បាស់មើល តើលោកចូលធ្វើការហ្នឹង លោកធ្វើការក្នុងឆ្នាំណាដែរ?

[១១:០៦:៤០]

**ធ៖** កាលខ្ញុំ ខ្ញុំចាំឆ្នាំមិនច្បាស់ វាយូរពេកហ្នឹង កាលជំនាន់នោះវាខ្ទង់បើមិន៧០ -- កាលហ្នឹងយន្តហោះនៅទម្លាក់ខ្លាំងនៅឡើយហ្នឹង ខ្ទង់៧០ -- ចុង៧៣, ៧៣ ចូល៧៤នុ៎ង។ វាចាំៗមិនច្បាស់ទេ ខ្ទង់ប៉ុណ្ណឹង *(ឮមិនច្បាស់)*។

**ស៖** ហើយពេលហ្នឹងលោក--

**ធ៖** ជម្រាបលោកស្រីទៅ ជំនាន់ហ្នឹងវានៅយន្តហោះនៅទម្លាប់នៅឡើយទេបាទ។

**ស៖** ពេលហ្នឹងលោកមានអាយុប៉ុន្មានដែរចាស?

**ធ៖** ពេលនោះ ដល់ឥឡូវ៦០ -- ទេ ៥៥ឆ្នាំ ៥៦ហ្នឹង។ កើតឆ្នាំ១៩៦០។

**ស៖** ចាស ហើយក្នុងពេលហ្នឹងលោកធ្វើជាអ្នកតាមដែលអ្នកបកប្រែឯកសារអង្គុលីលេខសម្ងាត់ ឬក៏លោកមានមុខងារធ្វើអ្វីផ្សេងទៀតដែរ?

**ធ៖** អត់មានទេបាទ។

**ស៖** ចុះលោកអត់មានបានរត់សំបុត្រពីឪពុកលោក ឬក៏ពីថ្នាក់ណាយកទៅថ្នាក់លើទៀតទេលោក?

**ធ៖** នៅៗតំបន់ហ្នឹង អត់មាននេះទេ នៅតែជាមួយឪពុកបាទ។

**ស៖** លោកគ្រាន់តែជាអ្នកបកប្រែ លោកអត់បានរត់សំបុត្រទេ អ៊ីចឹងលោក មែនឬក៏មិនមែន?

**ធ៖** អាហ្នឹងចង់សួរថានៅតំបន់១០៥ ឬក៏នៅកន្លែងផ្សេងទៀត ព្រោះប្រវត្តិវាវែងឆ្ងាយ ដល់ហ្នឹងទាល់តែយើង--

**ស៖** ចាស នៅក្នុងតំបន់១០៥។

**ធ៖** ក្នុងតំបន់១០៥ អត់ទេ។

**ស៖** ចាស ចុះពេលណាដែរ ដែលលោកធ្វើជាអ្នករត់សំបុត្រ?

**ធ៖** រត់សំបុត្រ អង្គាល់ -- មិនរត់សំបុត្រ -- ស្នាក់នៅហ្នឹងនៅកន្លែងមន្ទីរប-២០អីណោះទេ មិនមែននៅ១០៥ទេ។

**ស៖** ចាសៗ សូមអរគុណ។

**ឆ៖** បាទ។

**ស៖** ចុះក្នុងពេល អំឡុងពេលដែលលោកធ្វើការជាអ្នករត់សំបុត្រ តើលោកធ្លាប់រត់សំបុត្រពីកន្លែងណាទៅកន្លែងណាខ្លះដែរ? ហើយលោកធ្លាប់យកទៅឲ្យថ្នាក់ដឹកនាំណាខ្លះ?

**ឆ៖** កាលជំនាន់ហ្នឹង សួរថានៅ១០៥ ឬក៏នៅកន្លែងផ្សេង?

**ស៖** ចាស នៅពេលដែលលោករត់សំបុត្រធ្វើការនៅប-២០?

[១១:០៨:៥១]

**ឆ៖** បាទ នៅប-២០ នៅមន្ទីរប-២០ អាកន្លែងរត់សំបុត្រ មិនមែនរត់សំបុត្រឆ្ងាយទេ នៅបម្រើអ៊ំៗជំនាន់ហ្នឹង។ ហើយគាត់មានសំបុត្រអីតិចតួចហ្នឹង ទៅនៅ យកពីផ្ទះនេះ ទៅផ្ទះនោះអីចឹង។

**ស៖** ចាសៗអរគុណ។ ចាស លោកថាលោករត់សំបុត្រឲ្យអ៊ំៗ។ តើលោករត់ឲ្យអ៊ំណាខ្លះ លោកមានស្គាល់ឈ្មោះអ៊ំទេ?

**ឆ៖** មើលជំនាន់ហ្នឹងមានអ៊ំ នួន, អ៊ំ ប៉ុល អីហ្នឹង។

**ស៖** អ៊ំ នួន អ៊ំណាទៅលោក លោកបញ្ជាក់ឲ្យអស់មកលោក អ៊ំនួន, អ៊ំប៉ុល, អ៊ំអីហ្នឹង អ៊ំលោកបញ្ជាក់ឲ្យច្បាស់មើល?

**ឆ៖** អ៊ំប៉ុល – ប៉ុល ប៉ុល ពត ហ្នឹងណា។

**ស៖** ប៉ុល ពត។

**ឆ៖** បាទ។

**ស៖** ចុះអ៊ំនួន លោក?

**ឆ៖** អ៊ំនួន អ៊ំ -- ឥឡូវនេះហៅ នួន ជា ហ្នឹង។

**ស៖** ចាស នួន ជា។ ចាស ចុះក្រៅពីអ៊ំពីរនាក់ហ្នឹង តើលោកមានរត់ឲ្យអ៊ំណាខ្លះទៀត?

**ឆ៖** កាលហ្នឹងតាមចាំហ្នឹងមានផ្ទះមួយជួរហ្នឹងមានវាច្រើនគ្នាបាទ មានទាំងពី ហ៊ូ យន់, ហ៊ូ នឹម, ហើយលោក ខៀវ សំផន។ នៅជុំគ្នានៅហ្នឹង ដែលខ្ញុំនៅក្មេងៗ វាចងចាំនៅមិនៗច្បាស់ប្រាកដទេ ប៉ុន្តែប្រាកដអាត្រង់ថា ឃើញពួកគាត់ គាត់នៅនឹងខ្ញុំនៅមន្ទីរហ្នឹងដែរ។ ហើយនៅៗ ខ្ញុំនៅតូចអង្គាល់ហ្នឹង។

**ស៖** ចាសៗ អរគុណលោក។ ចុះសំបុត្រដែលលោករត់យកទៅឲ្យអ៊ំនួន ឬក៏អ៊ំ ខៀវ សំផន ហ្នឹង រាល់សំបុត្រដែលលោកបានទទួលមកហើយ សំបុត្រហ្នឹងលោករក្សាទុក ឬក៏បំផ្លាញចោល?

**ធ៖** អត់ទេយកឲ្យគាត់តើ។

[១១:១០:៣២]

**ស៖** យកឲ្យគាត់។ ចុះលោកដែលបានទទួលសំបុត្រដែលជាសារត្រឡប់មកវិញទេ?

**ធ៖** អត់មានទេ។

**ស៖** អត់មាន។ ចាស អរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតដែរថា តើលោកស្គាល់មន្ទីរ៨៧០ ទេលោក?

**ធ៖** ឮតែឈ្មោះទេបាទ--

**ស៖** ឮតែឈ្មោះ។

**ធ៖** --មិនបានដឹងថានៅត្រង់ណាឲ្យច្បាស់លាស់។

**ស៖** ចាសៗ។

**ធ៖** លេខ៨៧០នេះ ជាលេខទូទៅមកពីខាងលើទៅ គេដាក់៨៧០ អ៊ីចឹងតែម្តង។

**ស៖** ចាសៗ អរគុណ។ ចាស ចុះលោកនៅក្នុងក-១៧ នៅក្នុងតំបន់១០៥ ដែលឪពុកលោកគ្រប់គ្រង តើតំបន់១០៥ ហ្នឹងគ្រប់គ្រងនៅក្នុងខេត្តណាខ្លះដែរ?

**ធ៖** ១០៥ ហ្នឹងនៅខេត្តមណ្ឌលគិរីមួយទេ គេហៅតំបន់១០៥ តំបន់ស្វយ័ត ១០៥។

**ស៖** ចាស តំបន់ស្វយ័ត។ ចាស អរគុណ។ ចាស ចុះរាល់រចនាសម្ព័ន្ធនៃការរាយការណ៍ ដើម្បីដូចថា ឪពុកលោករាយការណ៍ពីរចនាសម្ព័ន្ធកន្លែងដែលឪពុកលោកគ្រប់គ្រងនោះ របៀបរាយការណ៍ហ្នឹង តើយើងរាយការណ៍ទៅថ្នាក់លើ រាយការណ៍របៀបម៉េចដែរលោក?

**ធ៖** រាយការណ៍តាមសារទូរលេខ។

[១១:១២:០២]

**ស៖** រាយការណ៍តាមសារទូរលេខ។

**ធ៖** ហើយគាត់មករៀនស្ទូត្រនៅភ្នំពេញហ្នឹង រាយការណ៍ខ្លួនឯងបាទ។

**ស៖** ចាស។ ចុះពាក់ព័ន្ធនឹងការរាយការណ៍ដែរ ពាក់ព័ន្ធ ឧទាហរណ៍លើពាក់ព័ន្ធៗផ្នែកសន្តិសុខ។ តើឪពុកលោករាយការណ៍ផ្ទាល់ទៅអ្នកណាដែរ ដែលទទួលបន្ទុកផ្នែកសន្តិសុខហ្នឹងលោក? លោកមានដឹងទេ?

**ធ៖** អត់បានដឹងទេបាទ។

**ស៖** ចាស អរគុណ។ ចាស ឆ្លងតាមបទពិសោធន៍ដែលលោកជាអ្នកបកប្រែសារទូរលេខសម្ងាត់ ខ្ញុំចង់ជម្រាបសួរលោកថា កន្លងមកហ្នឹងលោកដែលបានបកប្រែសារទូរលេខពាក់ព័ន្ធនឹងការសម្លាប់ ឬក៏ការបោសសម្អាតដែលផ្ញើពីថ្នាក់លើត្រឡប់ឱ្យលោកបកប្រែហ្នឹង លោកដែលបានជួបប្រទះទេចាស?

**ឆ៖** អត់បាន អត់ដឹងទេ ព្រោះលេខគេមិនដឹងគេដាក់លេខរហាត់ស្អី យើងអត់ ក្មេងៗគេមិនឱ្យដឹងទេ អ្នកបកក៏អត់ដឹងខ្លឹមសារអីដែរបាទ។

**ស៖** ចុះបើអ្នកបកអត់ដឹងខ្លឹមសារ ចុះៗលោកបកប្រែម៉េចទៅ? បើលោកជាអ្នកបកប្រែសារទូរលេខសម្ងាត់ ហើយសារទូរលេខសម្ងាត់ហ្នឹង តើគេប្រើជាម៉ូជាអក្សរ ឬក៏ម៉ូជាលេខ? សូមលោកបញ្ជាក់បញ្ហាហ្នឹង?

**ឆ៖** ម៉ូជាលេខបាទ បើសម្រាយធម្មតា វាបើយើងទៅទូទៅវាមានចេញជាលេខ ចេញជាអក្សរ បើថា អាសម្ងាត់មែនទែនគេមានលេខរហាត់របស់គេផ្សេងទៀត យើងមិនអាចដឹងបានទេ អ្នកបកក៏មិនអាចដឹងបានដែរ។

[១១:១៣:៣៧]

**ស៖** ចាស អរគុណ។ ចាស ចុះសារទូរលេខដែលលោកបកប្រែនោះ តើសារទូរលេខហ្នឹងយើង -- លោកច្រើនទទួលពីខាងណាដែរសម្រាប់លោកបកប្រែហ្នឹង?

**ឆ៖** ចេញពីមន្ទីរ៨៧០ ពី -- វាមានពីរប្រភេទមានមកពីខាងលើផង មកពីតាមស្រុក តាមខេត្តតាមស្រុក ហើយនិងតាមកងឯកភាពនៅតាមព្រំដែនអីចឹង។

**ស៖** ចាសៗ ចុះឯកសារដែលលោកបានឆ្លើយអម្បាញ់មិញលោកថា មកពីមន្ទីរ៨៧០ មកពីតាមស្រុកផ្សេងៗ។ ចុះឯកសារដែលផ្ញើៗចេញពីមន្ទីរ៨៧០ គេមានដាក់ឈ្មោះអ្នកណាដែលផ្ញើមកទេលោក មានដាក់ឈ្មោះមេដឹកនាំដែលថាត្រូវផ្ញើមកខាងលោក ឱ្យលោកបកប្រែ?

**ឆ៖** នៅចាំរហាត់អត់បានទេយូរ ជួនកាលមានឈ្មោះខ្លះ ឈ្មោះអ៊ំ មានភាគច្រើនឈ្មោះអ៊ំនួនដែលៗចេញឈ្មោះ។

**ស៖** ចាសៗ ចុះឯកសារដែលមកពីមន្ទីរ៨៧០ ដែលឈ្មោះអ៊ំនួន ភាគច្រើនឈ្មោះអ៊ំនួន ហ្នឹងឯកសារអស់ហ្នឹងច្រើនសំដៅទៅលើការងារ ផ្តោតទៅលើបញ្ហាអីដែរលោក?

**ឆ៖** ព្រោះអង្កាល់ហ្នឹងវាមានច្រើនប្រភេទ រឿងសន្តិសុខផង រឿង -- ខ្លះរឿងណែនាំរឿងទំនប់

01239116



រឿងប្រឡាយអីហ្នឹងបាទ។

[១១:១៥:00]

**ស៖** ចាស អរគុណ។ ចុះបើពាក់ព័ន្ធបញ្ហាសន្តិសុខ សន្តិសុខនោះ ដែលលោកច្រើនបកប្រែនោះ សន្តិសុខពាក់ព័ន្ធការបោសសម្អាត ការកម្ទេច ឬក៏អីដែរ ដែលលោកថាពាក់ព័ន្ធនឹងអី?

**ឆ៖** សន្តិសុខហ្នឹង គឺសំដៅលើព្រំដែន ដែលជំនាន់ខ្ញុំនៅហ្នឹង ព្រោះវាមានបញ្ហាធ្វើសង្គ្រាមតាមព្រំដែនហ្នឹង បាទ។

**ស៖** ចាស អរគុណ។ លោកបានជម្រាបជូនសហព្រះរាជអាជ្ញាកាលពីព្រឹកកន្លងមក ពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ឪពុកលោក។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថា ពីព្រោះលោកជាអ្នកនៅផ្ទាល់ជាមួយឪពុកលោក មិនអ៊ីចឹង?

**ឆ៖** បាទ។

**ស៖** ចាស អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថា មុនពេលដែលឪពុកលោកបាត់ខ្លួននោះ តើមានហេតុការណ៍អីកើតឡើងមុនហ្នឹងទេ? មានអ្នកណាឲ្យព័ត៌មានអីម៉េចៗ ឬក៏មានការណែនាំអីខ្លះៗ?

**ឆ៖** ចាំអត់បានទេ ជំនាន់ហ្នឹង មានផ្ទុះសង្គ្រាម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

អញ្ជើញលោក--

កុំអាលទាន់ឆ្លើយតប សាក្សី! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ <ខ្ញុំមិនច្បាស់ទេថា ហេតុអ្វីបានជា>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ប្រើពាក្យ "បាត់ខ្លួន"។ យើងដឹងច្បាស់ហើយនូវអ្វីដែលកើតឡើងចំពោះឪពុករបស់គាត់។ មានការផ្ដល់ភស្តុតាងថា ឪពុករបស់គាត់ ត្រូវបាន ខាំ ភួន ជាអ្នកសម្លាប់តើ។ ដូច្នេះ ពាក្យថា "បាត់ខ្លួន" នៅក្នុងករណីនេះ មិនសមស្របទេ ដូច្នេះ ខ្ញុំសូមជំទាស់ ចំពោះការប្រើពាក្យ "បាត់ខ្លួន" ឪពុកគាត់នេះ។

**លោកស្រី ស៊ីន សុវ៉ន៖**

ការជំទាស់របស់ខាងលោកមេធាវីការពារ -- អន្តរជាតិការពារលោក នួន ជា។ ចាស ចំពោះការដែលខ្ញុំសួរគាត់ពាក់ព័ន្ធនឹងការបាត់ខ្លួន ពីព្រោះគាត់បាននិយាយច្បាស់ហើយ គាត់ថា ឪពុកគាត់ហ្នឹង

បានទៅរៀនទៅភ្នំពេញ អង្គការបានហៅទៅរៀនសូត្រភ្នំពេញ ក៏បាត់ខ្លួនរហូត។ ហេតុហ្នឹងហើយបានខ្ញុំសួរថា មុនពេលដែលឪពុកគាត់ទៅរៀនភ្នំពេញនោះ ដែលបាត់ខ្លួន ដែលគាត់បាត់ខ្លួនឪពុកគាត់រហូតនោះ តើគាត់ដែលបានដឹងព័ត៌មាន ឬក៏ដែលបានឮសភាពការណ៍អីមុនហ្នឹង មានការណែនាំពីថ្នាក់លើមុនហ្នឹង ពីការបញ្ជូនឪពុកគាត់ទៅរៀនសូត្រនៅភ្នំពេញដែរឬទេ ចាស។

[១១:១៧:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី នួន ជា។ នេះគឺជាផ្អែកលើមូលដ្ឋាននៃសក្ខីកម្មរបស់រូបនេះ ដែលគាត់បានឆ្លើយដោយខ្លួនឯង ហើយបើសិនបើលោកមានព័ត៌មានផ្សេងផ្ទុយពីនេះ ចាំដល់វេនលោក លោកនឹងអាចទៅសួរផ្ទុញ់ ឬក៏សួរបញ្ជាក់លើចំណុចនេះ នាពេលក្រោយ។

សាក្សីឆ្លើយតបនឹងសំណួរដែលសួរចុងក្រោយ ដោយ -- សំណួរចុងក្រោយដែលសួរឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ។

**លោក ផាន វ៉ាន៖**

**ផ៖** មុននឹងឪពុកខ្ញុំបាត់ខ្លួន អត់មានបានដឹងព័ត៌មានអីទេ។ គ្រាន់តែដឹងថា គ្រាន់តែមានបញ្ហារង្គោះរង្គើតាមព្រំដែន ហើយនិងកូនរបស់អ៊ំភួនហ្នឹង គេចាប់។ កូនអ៊ំភួនហ្នឹងត្រូវចាប់ខ្លួន។ ហើយគេហៅមករៀននៅភ្នំពេញ មក ហើយគាត់ក៏ស្លាប់នៅកន្លែងមន្ទីរ១០៥ហ្នឹងបណ្ដោយ។ ដូចខ្ញុំបានជម្រាបលើកមុនអ៊ីចឹង។ បាទ សូមបញ្ជាក់ប៉ុណ្ណឹង។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស អរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរលោកបន្តថា លោក ក្រោយពេលដែលឪពុកលោកស្លាប់ហើយនោះ លោកមានគំនិត លោកមាន១គំនិតថាចង់គិត លោកមានគំនិតថា លោកនឹង១ស្វែងរកពីមូលហេតុនៃឪពុកលោកស្លាប់ហ្នឹងទេ?

**ផ៖** កាលជំនាន់ហ្នឹង ខ្ញុំនៅក្មេង វាមិនចេះគិតគូរអីច្រើនទេ គ្រាន់តែចង់ដឹងថា ហេតុអីបានសម្លាប់គ្នា បានស្លាប់។ ហើយគេថា គេផ្សាយថា អ៊ំ ខាំ ភួន នេះ ជាអ្នកសម្លាប់។ សម្លាប់ឪពុកខ្ញុំ ប៉ុន្តែរាល់គ្នាហ្នឹង អត់ជឿទេ ថាសម្លាប់ទៅ -- ត្រូវបងប្អូនខាងម្ដាយខ្ញុំ អ៊ំ ខាំ ភួន ហ្នឹង ហើយគាត់ហ្នឹង អ្នករួមរស់តស៊ូជាមួយគ្នាតាំងពីយូរណាស់មកហើយ ស្គាល់នៅជាមួយគ្នារហូតហ្នឹង។

[១១:១៩:០២]

**ស៖** ចាស អរគុណ។ ចាស អ៊ីចឹងមុនពេលដែលឪពុកលោក ដែលមកឲ្យរៀនភ្នំពេញ ឪពុកលោកជាមួយ ខាំភួន ហ្នឹងធ្លាប់ដែលមានបញ្ហាជាមួយគ្នាដែរឬក៏អត់លោក លោកមានបានដឹងទេ បញ្ហាហ្នឹង?

**ឆ៖** អត់បានដឹងទេ បាទ។ អត់ដែលឃើញមានបញ្ហាអីជាមួយគ្នាផង។

**ស៖** ចាស អរគុណ។ ចុះបន្ទាប់ពីឪពុកលោកស្លាប់ទៅ តើក្រុមគ្រួសាររបស់លោក ដូចជាបងស្រីលោក ខ្លួនលោកផ្ទាល់ហ្នឹង តើវាសនារបស់លោកហ្នឹងយ៉ាងម៉េចដែរ? បន្ទាប់ពីឪពុកលោកស្លាប់?

**ឆ៖** ខ្ញុំ បន្ទាប់ពីឪពុកខ្ញុំស្លាប់ខ្ញុំនៅភ្នំពេញរហូតបាទ។ គេឲ្យនៅកន្លែងដាំបន្លែនៅអរិយក្សត្រហ្នឹងមួយរយៈ ហ្នឹងបានមកៗនៅជាមួយ លោកស្រី អៀង ធីរិទ្ធ បាទ។

**ស៖** ចាស អរគុណ។ ចុះពេលដែលលោកមកធ្វើការជាមួយ លោកស្រី អៀង ធីរិទ្ធហ្នឹង លោកធ្វើការក្នុងឆ្នាំណាដែរ?

**ឆ៖** ក្រោយពីឪពុកខ្ញុំស្លាប់ហើយបាទ ខ្ញុំចាំឆ្នាំអត់បានច្បាស់។

**ស៖** ចាស អរគុណ។ លោកធ្វើការអីដែរ ជាមួយអ្នកស្រី អៀង ធីរិទ្ធហ្នឹង?

**ឆ៖** ទៅបើកឡានឲ្យគាត់បាទ។

**ស៖** ចាស អរគុណ។ លោកបានជូនគាត់ តើលោកធ្លាប់បើកឡានទៅ ទីៗកន្លែងណាខ្លះ លោកអាចជម្រាបអង្គជំនុំជម្រះបានទេ ចាស?

**ឆ៖** ខ្ញុំបើកឡានជូនគាត់តាមតែគាត់បញ្ជាឲ្យទៅៗតាមមន្ទីរពេទ្យ ទៅតាមអីហ្នឹងបាទ។

**ស៖** ចាស អរគុណ។ ចាស--

[១១:២១:៥៣]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់។ សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអន្តរាគមន៍ នៅក្នុងដំណាក់កាលនេះ ខ្ញុំតាមដានការសួររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ហើយលោកសាក្សីគាត់បានឆ្លើយរួចមកហើយ<នៅមុខអង្គជំនុំជម្រះតាំងពីដំបូងម្ល៉េះ ហើយការកោះហៅគាត់ត្រឡប់មកវិញនៅពេល>នេះ គឺនិយាយអំពីមន្ទីរសន្តិសុខភ្នំក្រោល។ ឥឡូវនេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មេធាវីសួរអំពី អៀង ធីរិទ្ធ វាអត់មានពាក់ព័ន្ធអីនឹងមន្ទីរសន្តិសុខភ្នំក្រោលទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងប្រធានបទដែលវាមិនពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង<00២/0២>របស់យើងនេះ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស អរគុណលោកប្រធាន ខ្ញុំសូមឆ្លើយតបនឹងលោកស្រីមេធាវី ការពារលោកខៀវ សំផន។ ចាស ការណ៍ដែលខ្ញុំសួរ--

**ប្រធានអង្គជំនុំ៖**

បន្តទៅមុខទៀតទៅ រឿងនោះវាផុតហើយ។ ប៉ុន្តែគប្បីពិនិត្យពីបញ្ហាបញ្ជាក់ច្បាស់លាស់គឺជៀសវាងឲ្យផុតពីការដែលសួរដេញដោលក្រៅអង្គហេតុចោទប្រកាន់ ឬក៏ក្រៅអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ នោះជាគោលការណ៍របស់វិជ្ជាជីវៈ អ្នកពាក់ព័ន្ធនឹងកិច្ចការដំណើរការរបស់អង្គ -- របស់តុលាការហើយ។

[១១:២៣:២៣]

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស អរគុណ លោកប្រធាន ខ្ញុំនឹងបង្វែរសំណួរផ្សេងចាស។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** លោកសាក្សី ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា ក្រោយពេលដែលឪពុកលោកស្លាប់ តើលោកមានដឹងពីការបាត់ខ្លួនអ្នកដែលធ្វើការក្រោមបង្គាប់របស់ឪពុកលោកហូរហែ លោកមានបានដឹងពីបញ្ហាហ្នឹងទេចាស?

**លោក ផាន វ៉ាន៖**

**ឆ៖** ក្រោយមកយូរបានដឹង។

**ស៖** ដឹងៗយ៉ាងម៉េចដែរចាស?

**ឆ៖** ដឹងតាមមិត្តភក្តិដែលគេចេញចូល។ គេប្រាប់ហើយថា អ្នកនោះបាត់ អ្នកនេះបាត់ខ្លួន ដែលគេចោទថាក្បត់ ថាអ៊ីចឹងទៅ។

**ស៖** ចាស អរគុណ។ ចាស លោកបានជម្រាបជាមួយលោកសហព្រះរាជអាជ្ញាកាលពីព្រឹកមិញថាប្រជាជននៅក្នុងតំបន់១០៥ ដែលឪពុកលោកគ្រប់គ្រងហ្នឹង មានប្រហែលជិត ១.000នាក់។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថា ក្នុងៗចំណោមប្រជាជនដែលជិតៗ ១.000 នាក់នោះ ចំពោះអាហារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហូបចុកនៅក្នុងឆ្នាំហ្នឹង តើប្រជាជនហ្នឹងហូបចុកគ្រប់គ្រាន់ទេលោក?

**ឆ៖** មិនមែន -- សូមបញ្ជាក់ថាមិនមែនៗក្នុងតំបន់១០៥ ទេបាទ គឺក្នុងៗមន្ទីរៗ ក-១៧ មន្ទីរតំបន់ហ្នឹង មនុស្សជិត ១.០០០ នាក់ បើតាមខ្ញុំចាំមិនខុសហ្នឹងណា។--

**ស៖** ចាសៗ។

**ឆ៖** --អាចតែខុស តួលេខតិចតួចទេបាទ។ តែម្ហូបអាហារអីវ៉ា អត់ៗខ្វះទេជំនាន់ហ្នឹង ហូបតាមសហករណ៍ហ្នឹង វាគ្រាន់ មានម្ហូបបានពីរពេល បីពេលដែរ អត់ខ្វះទេបាយ។

[១១:២៥:១០]

**ស៖** ចាស អរគុណ ។ លោកបានឆ្លើយជាមួយសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការចាប់មនុស្សដាក់មកមន្ទីរសន្តិសុខទំនប់ភ្នំក្រោល ថាអ្នកដែលចាប់មកច្រើនខុសសីលធម៌ ខុសអីចឹង។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា កន្លងមកនៅមន្ទីរក-១៧ៗហ្នឹង តើមានការខុសសីលធម៌ច្រើន ឬក៏ម៉េចដែរ?

**ឆ៖** នៅក-១៧ កាលជំនាន់ខ្ញុំនៅ គឺអត់មានខុសសីលធម៌អីច្រើនទេ ប៉ុន្តែការអប់រំហ្នឹង គេអប់រំរហូតពីរឿងសីលធម៌។

**ស៖** ចាស អរគុណ។ ចាស អ៊ីចឹងនៅ ខ្ញុំចង់ជម្រាបសួរលោកបន្ត ពាក់ព័ន្ធនឹងការឡើងប្តេជ្ញាចិត្ត។ ចុះនៅមន្ទីរក-១៧ ដែលមានប្រជាជនជិត ១.០០០នាក់ ក្នុងសម័យហ្នឹង តើអង្គការមានបានផ្តួផ្គងឲ្យយុវជន យុវនារីហ្នឹងឡើងប្តេជ្ញាចិត្តដែរ?

**ឆ៖** ប្តេជ្ញាចិត្តរឿងៗស្អី គ្រាន់ៗចង់បញ្ជាក់។

**ស៖** ប្តេជ្ញាចិត្តការជ្រើសរើសគូស្រករអីហ្នឹងណ៎ាលោក រៀបការប្តេជ្ញាចិត្តការរៀបការហ្នឹង?

**ឆ៖** រៀបការ មានៗជាធម្មតា អ្នករៀបការ អ្នកណាគ្រប់អាយុគេរៀបការឲ្យ។

**ស៖** ដែលលោកមានប្រសាសន៍ថា អ្នកគ្រប់អាយុគេរៀបការឲ្យ។ "គេ"ហ្នឹង គេអ្នកណាដែរលោក? លោកអាចបញ្ជាក់បានទេ?

**ឆ៖** ប្រធានមន្ទីរហ្នឹងបាទ ប្រធានមន្ទីរមួយៗគេមានសិទ្ធិស្នើទៅនឹងអង្គការអ៊ីចឹងទៅ គេសម្រេចទៅអ្នកនេះឲ្យរៀបការ អ្នកនោះឲ្យរៀបការអ៊ីចឹងទៅ។

**ស៖** ចាសៗ អរគុណ។ អ៊ីចឹងតាមការសង្កេតរបស់លោកកន្លងមកនោះ ខ្ញុំចង់ជម្រាបសួរថា អ្នកដែលប្រធានមន្ទីរស្នើឲ្យរៀបការ ពួកគេទាំងពីរនាក់ហ្នឹង ពួកគេត្រូវរ៉ូវគ្នាដែរ ឬក៏ពួកគេមានការស្នើសុំមកប្រធានមន្ទីរ ឬក៏ប្រធានមន្ទីរយល់ឃើញថា អ្នកនឹងពេញវ័យហើយត្រូវតែអង្គការរៀបគូស្រករ

ឱ្យ?

[១១:២៧:១៨]

**ឆ៖** ជំនាន់ហ្នឹងមានអង្គការរៀបឱ្យ។

**ស៖** ចាសៗ អរគុណ។ ចុះៗ ចំពោះលោក លោករៀបការក្នុងឆ្នាំណាដែរ?

**ឆ៖** ខ្ញុំការឆ្នាំ៨៥។

**ស៖** ចាសៗ អរគុណ។ ចាស អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកបន្ត លោកដែលបានសង្កេតឃើញអ្នកដែលអង្គការរៀបការឱ្យនោះ ពួកគាត់មានការពេញចិត្តនឹងគូស្រករបស់គាត់មួយៗហ្នឹងដែរ?

**ឆ៖** អ្នកខ្លះក៏ពេញចិត្ត អ្នកខ្លះក៏នៅជាមួយគ្នាដោយបង្ខំអ៊ីចឹងទៅ ចេះតែទ្រាំនៅបើគេចាត់តាំងហើយធ្វើម៉េច កាលជំនាន់ហ្នឹងអ្នកណាក៏ដឹងដែរ តែបើគេឱ្យធ្វើអីហើយត្រូវតែធ្វើ អត់ធ្វើម៉េចបានកសាងខ្លួនអត់ឡើងទៀតឥឡូវ។

**ស៖** ចាស អរគុណលោក។ ចុះកន្លងមកលោកដែលឃើញអ្នកដែលថាមិនព្រម អ្នកដែលប្រឆាំងនឹងអង្គការនោះ។ ឧទាហរណ៍ ដូចអង្គការឱ្យរៀបការគាត់មិនព្រម តើមានអ្វីកើតឡើងចំពោះរូបគាត់ លោកដែលបានសង្កេតឃើញទេបញ្ហាហ្នឹង?

**ឆ៖** នៅ១០៥ មានករណីមួយកើតឡើងដែរ បាញ់ខ្លួនឯងស្លាប់ ខាងយោធាស្រឡាញ់នារីម្នាក់អ៊ីចឹងទៅ ហើយអត់បានការ ដល់អ៊ីចឹងសម្លាប់ខ្លួន។ ហ្នឹងមានករណីតែម្នាក់ទេ កាលជំនាន់ហ្នឹង។

**ស៖** ចាស អរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតដែរ ថាលោកៗមានស្គាល់ឈ្មោះ សុនវុត ទេចាស? ជាប្រធានវីរអនុសេនាធំនៅក្នុងតំបន់ហ្នឹងណាលោក?

**ឆ៖** អត់ស្គាល់ផង។

**ស៖** ចាស អរគុណៗ លោកសាក្សី ខ្ញុំអស់សំណួរសួរហើយ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស អរគុណលោកប្រធានខ្ញុំអស់សំណួរសួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអរគុណលោកសាក្សី ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អរគុណផងដែរ

លោក សុភារិទ្ធ អំមិញច្រទ្បំថាលោក ញ៉ែម សំណាង តាមពិតលោក សុភារិទ្ធ ទេ។ អង្គជំនុំជម្រះក៏អរគុណក្នុងការរៀបចំរបស់លោក ប៉ុន្តែឥឡូវនេះ លោកអាចសម្រាកថ្ងៃត្រង់បានហើយ ចាំម៉ោងមួយកន្លះសូមបន្តដំណើរការសវនាការ។ ហើយម៉ោង -- មុនម៉ោងមួយកន្លះ សូមលោកទាំងពីរមានវត្តមាននៅកន្លែងផ្តល់សក្ខីកម្មណ៎ះ! លោកស្តាប់បានទេ?

**លោក ផាន វ៉ាន៖**

បាទ។

**លោក ជួង សុភារិទ្ធ៖**

បាទ ស្តាប់បានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សួស្តីលោកសាក្សី តើលោកបានត្រៀមខ្លួនរួចហើយឬនៅ?

**លោក ផាន វ៉ាន៖**

ត្រៀមរួចហើយ។

**ប្រធានអង្គជំនុំ៖**

បានត្រៀមខ្លួនរួចហើយឬនៅ សាក្សី?

**លោក ផាន វ៉ាន៖**

ត្រៀមខ្លួនរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ដំបូងនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរ លោកប្រធាន លោក លោកស្រីចៅក្រម។

**ស៖** ជម្រាបសួរ លោកសាក្សី ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ជាមេធាវីការពារក្តីអន្តរជាតិឲ្យលោក នួន ជា។ ខ្ញុំមានសំណួរខ្លះសួរទៅកាន់លោកនៅរសៀលនេះ។ ខ្ញុំសូមចាប់ផ្តើមសួរនូវអ្វីដែលលោកបានឆ្លើយជាងបីឆ្នាំកន្លះមកហើយ នៅចំពោះមុខអង្គជំនុំជម្រះយើងនេះ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ គឺឯកសារ <E1/151> នៅប្រហែលជា<១៥:៤៤> រសៀល លោកត្រូវបានសួរអំពីសារទូរលេខ។ ហើយលោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្តីលោកតែម្តង៖ "ស្ថានភាពនៅពេលនោះ គឺថាមានភាពតឹងតែងណាស់ ហើយយើងត្រូវតែធ្វើតាមការណែនាំឲ្យបានហ្មត់ចត់បំផុត។ នៅពេលនោះ មាន<ខ្មាំង>វាយប្រយុទ្ធជាមួយកងទ័ពរបស់យើងនៅតាមព្រំដែន ហើយក៏មានសង្គ្រាមនៅក្នុង<>ក្រុមផ្សេងៗគ្នា ខាងផ្ទៃក្នុងយើងដែរ។ ហេតុដូច្នេះហើយ បានជាយើងធ្វើយ៉ាងណាក៏ដោយ ត្រូវតែប្រកាន់ខ្ជាប់ទៅតាមការណែនាំ។ បើសិនជាខ្ញុំត្រូវរៀបរាប់លម្អិតអំពីស្ថានភាពខ្មាំងនៅពេលនោះគឺថាវែងឆ្ងាយណាស់ ដោយសារមានសមាសធាតុខ្មាំងច្រើនណាស់ នៅពេលនោះ។ តាមខ្ញុំយល់ ខ្មាំងជ្រៀតចូលផ្ទៃក្នុង គឺពួកដែលមិនដើរតាមមតិណែនាំ ការណែនាំរបស់បក្ស អ្នកដែលងាកចេញពីការណែនាំ។ ដូច្នេះអ្នកទាំងអស់នេះ គឺថាអង្គការលែងទុកចិត្តទៀតហើយ។ ហើយអង្គការក៏មិនឲ្យភារកិច្ចអ្វីឲ្យពួកគេធ្វើដែរ។ បន្ថែមលើនេះទៀត ក្នុងកាលៈទេសៈខ្លះ ពួកគេក៏ត្រូវបានឃុំឃាំងខ្លួនផងដែរ។ នេះជាការយល់ឃើញរបស់<អង្គ-ការ>។ ហើយ<អ្នកទាំងនោះត្រូវបានចាត់ទុកថា ចូលទៅ>ខាង<>ខ្មាំង។ ពួកគេមិនមែនជាខ្មាំងទេ> គឺខ្មាំងវៀតណាមដែលវាយប្រយុទ្ធយើងនៅតាមព្រំដែន។" នេះគឺជាសម្រង់មួយវែងឆ្ងាយណាស់ លោកសាក្សី ក៏ប៉ុន្តែលោកនៅចាំទេថា លោកបានឆ្លើយជូនអង្គជំនុំជម្រះនៅខែធ្នូ ឆ្នាំ២០១២ ថាយ៉ាងដូច្នេះឯងលោកបាន លោកចាំទេ?

**លោក ផាន វ៉ាន់៖**

**ឆ៖** ចាំ បាន បាទ។

[១៣:៣៨:១៦]

**ស៖** ឥឡូវនេះយើងមានពេលវេលាច្រើនបន្ថែមទៀត ដើម្បីពិភាក្សាគ្នាទៅលើបញ្ហានេះតែម្តង។ តើលោកចង់និយាយថាម៉េចលោក នៅពេលដែលលោកនិយាយថា "នៅពេលនោះ មានខ្មាំងវាយប្រយុទ្ធជាមួយនឹងកងទ័ពរបស់យើង<>នៅតាមព្រំដែន។" តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ<អ្វីខ្លះ អំពី>ការវាយប្រយុទ្ធនៅតាមព្រំដែន ខ្ញុំគិតថា គឺជាការប្រយុទ្ធពីសំណាក់វៀតណាម ជាមួយនឹងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ។ <>លោកនៅទីកឃើញអ្វីខ្លះដែរ?

**ឆ៖** នឹកឃើញតែការវាយគ្នានេះជាមួយកងទ័ពវៀតណាម។

**ស៖** ចុះលោកចាំអ្វីឲ្យបានជាក់លាក់? <តើ>លោកចាំអំពីហេតុការណ៍ណាមួយ ការប្រយុទ្ធណាមួយ? បើលោកចាំបាន តើលោកចាំអ្វីឲ្យជាក់លាក់នោះលោក?

**ឆ៖** ចាំអត់បានទេ ប៉ុនគ្រាន់តែចាំថា មានការប្រយុទ្ធ។

**ស៖** ចុះធ្វើយ៉ាងដូចម្តេចទើបលោកបានដឹងថា មានការវាយប្រយុទ្ធគ្នានៅតាមព្រំដែនរវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពវៀតណាម?

**ឆ៖** ស្តាប់សំណួរអត់បាន។

[១៣:៤០:០៣]

**ស៖** តើនៅពេលនោះ លោកដឹងថាមានការវាយប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ពកម្ពុជាប្រជាធិបតេយ្យ លោកដឹងដោយរបៀបណា អ្នកណាប្រាប់លោក? លោកដឹងព័ត៌មាននេះពីប្រភពណាដែរ?

**ឆ៖** ឮកាំភ្លើង ឮរហូតហ្នឹងបាទ។

**ស៖** ក្រៅពីនេះ តើលោកនៅចាំអ្វីខ្លះទៀត?

**ឆ៖** អត់ចាំផងបាទ។

**ស៖** មិនបញ្ហាអ្វីទេ ឥឡូវខ្ញុំសូម<>ជួយរំឭកដល់ការចងចាំរបស់លោកខ្លះៗ។ ព្រឹកមិញ នេះសហព្រះរាជអាជ្ញាបានអានសម្រង់ចេញពីសារទូរលេខមួយឲ្យលោកស្តាប់ ដែលឪពុករបស់លោកជាអ្នកផ្ញើចេញ គឺផ្ញើបញ្ជូនមកឲ្យមន្ទីរ៨៧០ គឺឯកសារ E3/877។ លោកបានទទួលស្គាល់ថា ពិតជាមានសារទូរលេខនេះមែន ហើយឪពុករបស់លោកពិតជាបានផ្ញើចេញមែន។ ខ្ញុំមានសំណួរមួយពាក់ព័ន្ធនឹង

សារទូរលេខនេះ <ហើយបន្ទាប់មក>ខ្ញុំនឹងសួរ<អំពី>ទូរលេខមួយផ្សេងទៀត។ សារទូរលេខនេះគឺចុះហត្ថលេខាដោយឈ្មោះ ឆាន់។ ឪពុករបស់លោក គេហៅគាត់ថា ហំ ហៅ ឡាំង។ តើលោកដឹងទេ នៅពេល<ណា>គាត់ប្រើ<>ឈ្មោះមួយណា? តើគាត់ប្រើ<តែ>ឈ្មោះ ឆាន់ <ទេឬពេលដែលគាត់ចុះហត្ថលេខាលើសារទូរលេខ? តើគាត់>ប្រើ<ជាមួយអ្នកផ្សេងទៀត>តែឈ្មោះ ឡាំង មួយទេ? តើលោកអាចជម្រាបបញ្ហានេះបន្តិចបានទេ?

**ឆ៖** ពីមុនឈ្មោះៗ ឡាំង ក្រោយមកគេឲ្យ -- គេដូរបានដូរដាក់ឈ្មោះ ឆាន់ វិញ មិនដឹងហេតុផលអីទេ ខ្ញុំៗក៏មិនយល់ដែរ។

**ស៖** តើលោកដែលដឹងថាគាត់ប្រើឈ្មោះគាត់ ហំ ផងដែរទេ?

**ឆ៖** ហំ អត់ដែលប្រើទេ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅសារទូរលេខដែលខ្ញុំចង់សួរសំណួរខ្លះៗពាក់ព័ន្ធគឺឯកសារ E3/1030 ERN អង់គ្លេស 00324806, ខ្មែរ 00033312, បារាំង 00623150។ នេះជាសារទូរលេខ ផ្ញើទៅឲ្យឪពុករបស់លោកចុះថ្ងៃទី២០ មិថុនា ឆ្នាំ៧៧ ដែលផ្ញើចេញ ឬក៏ចុះហត្ថលេខាដោយ តាសុភា ខ្ញុំសូមអានសម្រង់ខ្លីមួយទេចេញពីសារទូរលេខនេះ ហើយខ្ញុំនឹងសួរសំណួរខ្លះៗអំពីសារទូរលេខនេះ "ជូនបងឆាន់ជាទីស្នេហា និងនីករព្យក យើងខ្ញុំសូមរាយការណ៍អំពីសភាពការណ៍ពួក៧ ដូចតទៅនេះ៖ ១) មុខព្រួញអូរផ្លាយ វាបានចូលដីយើងចំនួន២០ម៉ែត្រ ហើយបានមកកាប់ឫស្សីយើង យើងបានវាយពួកវាស្លាប់ និងរបួសមួយចំនួននៅថ្ងៃទី១៧ ខែមិថុនា ៧៧ ហើយយើងបន្តវាយវានៅ<ព្រឹក>ថ្ងៃទី១៥ ខែមិថុនា ៧៧ នេះទៀត<ដោយបានសម្លាប់ និងធ្វើឲ្យពួកវារបួសជាច្រើន>។ ពួកវាមានច្រើនដល់ជាង១០០នាក់ ឥឡូវនេះវាមិនទាន់ដកទេ ហេតុដូច្នេះហើយយើងចាត់ចែងកម្លាំងយើងថែមទៀត ហើយពួកវាចូលដីយើងចំនួន៥០០ម៉ែត្រទៀត។ ២) ពួក៧ ដែល<វាយប្រហារយើងនៅពេជ្រាដា ឥឡូវនេះ -->

**ប្រធានអង្គជំនុំ៖**

ឈប់! អត់មានការបកប្រែភាសាខ្មែរ?

អញ្ជើញតទៅទៀត លោកមេធាវី វ៉ិចទ័រ កូប៉េ។ ខ្ញុំអស់ថ្មទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <ចំណុចទី២ នៅក្នុងសារទូរលេខនេះនិយាយថា៖ "២) ពួក៧ ដែលវាយយើងនៅពេជ្រាដានោះ ឥឡូវ<បានវាយ>ចូលមកភូមិពូជ្រីចាស់ និងភូមិតុញ និង<ភូមិ>ដេអេ គ្នាវាមានប្រហែល៣០

នាក់។" លោកសាក្សីតើលោក<យល់ពីសម្រង់របស់>សារទូរលេខនេះ< ដែលគេផ្ញើ>ឲ្យឪពុករបស់លោក<>ទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ អាហ្នឹង *(ឮមិនច្បាស់)*។

[១៣:៤៥:៥៤]

**ស៖** ចុះលោកមានដឹង<អ្វីខ្លះទេ>អំពីការ<ឈ្លានពាន ឬការ>វាយលុកចូលពីសំណាក់វៀតណាមមកក្នុងបូរណភាពដែនដីកម្ពុជាប្រជាធិបតេយ្យទេ <ដូច>ដែលខ្ញុំទើបនឹងអាននេះ? តើវាមានជួយរំឭកដល់ការចងចាំរបស់លោក ហើយវាពាក់ព័ន្ធដល់ការវាយប្រហារណាផ្សេងទៀតដែរទេ?

**ឆ៖** ស្តាប់អត់បានច្បាស់។

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញ។ បើលោកមិនចាំព្រឹត្តិការណ៍នេះ លោកមានចាំព្រឹត្តិការណ៍ណាប្រហាក់ប្រហែលគ្នាស្តីអំពីការវាយលុកលុយពីសំណាក់វៀតណាម ចូលមកក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យដែរទេ?

**ឆ៖** ចាំបានៗត្រង់ថា មានការវ៉ៃចូល។

**ស៖** នៅក្នុងសារទូរលេខនេះ គឺថាបានប្រើប្រាស់ពាក្យនេះ ចំនួនពីរដង គឺពាក្យថា "ពួក៧ គឺការវាយប្រយុទ្ធពីសំណាក់ពួក៧"។ តើលោកដឹងថា ពួក៧ <មានន័យថាម៉េចទេ? តើអ្នកណាជា>ពួកប្រាំពីរ<> ដែល<>វាយប្រយុទ្ធមកលើកងទ័ពកម្ពុជាប្រជាធិបតេយ្យនេះ<>? ហើយលោកដែលឮពាក្យនេះទេ "ពួក៧"?

**ឆ៖** អត់ដែលឮទេ។

**ស៖** <តើ>ពាក្យថា "ពួក៧ ឬក្រុម៧" គឺជាពាក្យមួយដែលគេយកមកប្រើប្រាស់ជាញឹកញាប់<ទេ>នៅក្នុងសារទូរលេខ? តើលោកអាចពន្យល់ជូនតុលាការបានទេ នៅក្នុងពេលដែលលោកបកប្រែសារទូរលេខនុ៎ង <> លោកមិនដែលឮពាក្យ "ពួក៧" នេះ?

**ឆ៖** អត់ដែលឮទេបាទ។

[១៣:៣៨:៥២]

**ស៖** បាទ ដើម្បីឲ្យវាលឿនទៅមុខបន្តិច។ ខ្ញុំសូមអានសម្រង់មួយចេញពីសក្ខីកម្មរបស់<>ទាហានកងពល៩២០ម្នាក់ ដែលបានមកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះកាលពីសប្តាហ៍មុន។ ដំបូងខ្ញុំអានឲ្យលោកស្តាប់សិន ហើយសួរលោកមើលថា តើលោកយល់ស្របជាមួយនឹងចម្លើយរបស់គាត់នេះ ឬក៏

លោកមិនយល់ស្របទេ? លោកប្រធាន នេះគឺឯកសារជាប្រតិចារឹក នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ នៅម៉ោង១១:០១ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ សុន វុត។ <លោកសាក្សី ខ្ញុំបាន>សួរដើមបណ្ដឹងរដ្ឋ-ប្បវេណី<នេះ>ដូចតទៅ៖ “តើលោកយល់ស្របជាមួយខ្ញុំទេ ដែលថា<កងកម្លាំង>វៀតណាម <ចូល>មក<ក្នុង>កម្ពុជាប្រជាធិបតេយ្យ <ឈ្លានពានទឹកដីកម្ពុជាប្រជាធិបតេយ្យ> វាយប្រយុទ្ធមកលើកម្ពុជាប្រជាធិបតេយ្យជាហូរហែ? តើខាងវៀតណាម ឬដែលចាប់ផ្ដើមធ្វើសកម្មនេះ? ហើយចម្លើយរបស់កងទ័ពកងពល៩២០ ឆ្លើយដូចតទៅ ៖ “បាទ គឺវៀតណាម ដែលចាប់ផ្ដើមវាយប្រហារយើងដែលចូលមកក្នុងដែនដីរបស់យើង។ សម្រាប់យើងពីខាងភាគីកម្ពុជា យើងមិនដែលលុកលុយចូលទៅក្នុងទឹកដីវៀតណាមទេ ហើយពួកគេលុកលុយចូលមកក្នុងទឹកដីយើង។ ហើយគេអះអាងថា ទឹកដីនោះជាទឹកដីរបស់គេ ទោះបីជាមានទឡ្ហក់ បង្គោលទឡ្ហក់ បង្គោលព្រំដែននៅអូរដាក់ដាំនោះក្ដី ហើយគេ<ចូលមកតំបន់ទុយោសាំង។ ប៉ុន្តែពួកគេបាន>អះអាង<នៅពេលមួយ>ថា ទឹកដីរបស់គេចូលរហូតទៅដល់<៥ទៅ២០>គីឡូឯណោះមកក្នុងទឹកដីយើង។ អ៊ីចឹងឯងបានទើបជាមានការបន្តវាយប្រយុទ្ធគ្នាឥតឈប់ឈរនៅពេលនោះ។” បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំលោកសាក្សី តើលោកយល់ស្រប ឬក៏មិនយល់ស្របជាមួយនឹងចម្លើយរបស់កងទ័ពមកពីអតីតកងពល៩២០ ដែលឆ្លើយជូនអង្គជំនុំជម្រះកាលពីសប្ដាហ៍មុន លោកយល់ស្រប ឬមិនយល់ស្រប?

[១៣:៥១:២៤]

**ឆ៖** យល់ស្រប វៀតណាមវ៉ៃចូលមែន។

**ស៖** ចុះលោកយល់ស្រប<នឹងអ្វីដែល>ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់នេះ<និយាយទេ ឬក៏យ៉ាងហោចណាស់ពាក់ព័ន្ធនឹងថា វាពិតជាភាគី>វៀតណាម ដែលតែងតែចាប់ផ្ដើមឈ្លានពានមកលើកម្ពុជាប្រជាធិបតេយ្យ។ លោកយល់ស្របទេ ឬមិនយល់ស្របទេ?

**ឆ៖** ខ្ញុំមិនយល់ៗទេបាទ។

**ស៖** លោកមិនយល់ ឬលោកមិនយល់ស្រប ហើយមូលហេតុអីលោក មូលហេតុអី?

**ឆ៖** អត់យល់ អត់យល់ពាក្យដែលថា គេមាន គេចង់ចូលរំលោភលើដីខ្មែរ ឬក៏យ៉ាងណានោះខ្ញុំអត់ៗយល់ទេបាទ។ យល់ដឹងដែលថាមានការវ៉ៃចូលតែប៉ុណ្ណឹង។

**ស៖** យល់ហើយ បាទ ខ្ញុំយល់ហើយ។ សូមអរគុណលោកសាក្សី។ ខ្ញុំសូមបន្តទៅផ្នែកទី២ នៃចម្លើយរបស់លោក ដែលលោកបានឆ្លើយបីឆ្នាំកន្លះមកហើយ គឺលោក<>មិនមែនត្រឹមតែនិយាយពីខ្លាំង

ខាងក្រៅ<គឺវៀតណាម>ទេ <តែ>ក៏និយាយពីខ្មាំងផ្ទៃក្នុងដែរ។ លោកនិយាយពី<ផ្នែកខុសៗគ្នា ហើយលោកបាននិយាយអំពី>ក្រុមផ្សេងៗគ្នា។ តើលោកចង់និយាយថាម៉េចនៅពេលដែលលោកនិយាយថាមានបក្សផ្សេងគ្នា មានក្រុមផ្សេងគ្នានៅខាងក្នុង។ តើលោកចង់និយាយដូចម្តេចដែរត្រង់ចំណុចនេះ?

**ឆ៖** អត់យល់សំណួរបាន។

**ស៖** នៅដើមដំបូងនោះ គឺខ្ញុំបានអានសម្រង់មួយ <>ចេញពីចម្លើយរបស់លោកផ្ទាល់តែម្តង ហើយ<លោកយល់ស្របនឹងចម្លើយនោះ។ ហើយ>នៅក្នុងចម្លើយដែលលោកឆ្លើយហ្នឹង គឺលោកនិយាយអំពីខ្មាំងផ្ទៃក្រៅគឺវៀតណាម ហើយលោកក៏និយាយអំពីខ្មាំងផ្ទៃក្នុងដែរ ហើយជាពិសេសខ្មាំងផ្ទៃក្នុងនេះ លោកប្រើពាក្យថា ដោយសារតែមានក្រុមផ្សេងគ្នា មានបក្សផ្សេងគ្នានៅខាងក្នុង។ តើលោកចង់និយាយថាម៉េច នៅពេលលោកប្រើពាក្យថា “ជាផ្ទៃក្នុង គឺថាមានបក្សពួកផ្សេងគ្នា មានក្រុមផ្សេងគ្នា”?

[១៣:៥៤:១៧]

**ឆ៖** ដូចខ្ញុំមិនបាននិយាយថាពួកបក្សផ្សេងទេ អត់ទេ ដូចអត់មាននិយាយទេ មានតែខ្មាំងផ្ទៃក្នុង គេចោទថាខ្មាំងផ្ទៃក្នុង ហើយថាអ្នកណាអត់ៗធ្វើតាមគេបញ្ជារហ្នឹង គេថាខ្មាំងផ្ទៃក្នុងហើយអាហ្នឹងនោះ។ សូមបញ្ជាក់បុណ្ណឹង។

**ស៖** ចុះអ្នកដែលត្រូវបានគេចោទថាចូលដៃជាមួយវៀតណាម តើគេចាត់ទុកអ្នកទាំងនេះថាជាខ្មាំងខាងក្រៅដែរទេ<>?

**ឆ៖** អត់ទេបាទ គេហៅ គេថាខ្មាំងផ្ទៃក្នុង។

**ស៖** <ខ្ញុំមិនច្បាស់ថាតើមាន>ការបកប្រែ<ត្រឹមត្រូវឬទេលោកប្រធាន>។ ខ្ញុំបានចម្លើយមកហាក់បីដូចជាផ្សេងទៅវិញ ដែលហាក់បីដូចជាថាគាត់មិនយល់សំណួរទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំក៏ឮដូចលោកដែរ។ ដោយសារតែបញ្ហានេះលោកឃើញបញ្ហាក្រោកក្រាកនេះ អ៊ីចឹងលោកសួរឲ្យខ្លីៗបន្តិចៗទៅ។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ចាប់ផ្តើមសួរសាជាថ្មីលោកសាក្សី។ <តើ>ខ្មាំងផ្ទៃក្នុង គឺគេសំដៅទៅលើ<>អ្នកចូលដៃជាមួយវៀតណាមឬ?

**លោក ផាន វ៉ាន៖**

**ឆ៖** អាហ្នឹងមិនកំណត់ទេ ឲ្យតែថាអ្នកអត់ឯកភាពជាមួយគេៗ ថាគេចាប់ គេចោទថាខ្មាំងវៀតណាមអីចឹងតែម្តង។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់ឮពាក្យថា "ចលនាខាំភួន" ដែរទេ?

**ឆ៖** ថាម៉េចបាទ? ចាំអត់ច្បាស់ បញ្ជាក់ម្តងទៀត។

**ស៖** តើលោកធ្លាប់ឮចលនាបះបោរមួយ ដែលដឹកនាំដោយ ខាំភួន ពាក់ព័ន្ធនឹងកងពល៩២០ គេហៅថា "ចលនាខាំភួន" លោកដែលឮទេ?

**ឆ៖** អត់ដែលឮទេ។

**ស៖** តើលោកដឹង<ទេ>ថា ខាំ ភួន គឺអ្នកដែលគេចោទថា សម្លាប់ឪពុកលោកនោះណា<ត្រូវបានគេចោទថា>ជាជនក្បត់<>?

**ឆ៖** កាលៗដំបូងអត់ដឹងទេ ដល់ក្រោយពីស្លាប់មកបានគេប្រកាសថា "ក្បត់" សម្លាប់ឪពុកខ្ញុំតែប៉ុណ្ណឹង។

[១៣:៥៨:១៧]

**ស៖** <តើលោកបានឮអ្វីខ្លះអំពី>ការចោទប្រកាន់ពាក់ព័ន្ធទៅនឹង ខាំ ភួន នេះ? តើលោកដឹងថាគេមានចោទប្រកាន់ទៅលើ ខាំ ភួន នេះ<>ពីអ្វីជាក់លាក់ដែរទេ?

**ឆ៖** ឮគេប្រកាសប្រាប់ហ្នឹងចោទថា *(ឮមិនច្បាស់)*។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយម្តងទៀត លោកឆ្លើយអំមិញគឺស្តាប់ភាសាខ្មែរអត់ច្បាស់ទេ។

**លោក ផាន វ៉ាន៖**

**ឆ៖** ខ្ញុំឆ្លើយថា ក្រោយពីប៉ាគាត់ស្លាប់ហើយ បានៗគេប្រកាសប្រាប់ថា "ខាំភួន ហ្នឹងជាខ្សែវៀតណាម"។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ចុះលោកមានដឹងថាគេចោទប្រកាន់គាត់ឲ្យចំៗពីបទអ្វីដែរ? តើគេចោទគាត់ឲ្យចំៗពីសកម្មភាពអ្វីដែរ? <តើគាត់បានធ្វើអ្វីឲ្យជាក់លាក់នោះ?>

**ឆ៖** អត់មានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំនៅតែបារម្ភអំពីការបកប្រែ ហើយខ្ញុំបានទទួលសារថា <នឹង>ដាច់ភ្លើងដាច់អីនៅសណ្ឋាគារនោះផង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<យើងមិនទាន់ដឹងនៅឡើយទេ។ យើងនៅពេលនេះកំពុងតែប្រើថ្ម។ ពួកគេសង្ឃឹមថា នឹងមានភ្លើងប្រើវិញ។> លោក<បន្តទៀត>ចុះ នៅពេល<នេះថ្មកំពុងដំណើរការ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំព្យាយាមសួរតាមរបៀបផ្សេង។ តើលោកដែលឮគេចោទប្រកាន់ ខាំ ភួន និងស្វាយ, កាស៊ី ថាអ្នកទាំងនេះ ជាអ្នកជួយចិញ្ចឹម និងជាជួយទៅដល់កងទ័ពវៀតណាម ហើយជាអ្នកនាំយកកងទ័ពវៀតណាម ចូលមកក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ។ លោកដឹង លោកឮដែរទេ?

**លោក ផាន វ៉ាន់៖**

**ឆ៖** ឮដែលគេថាទាក់ទងជាមួយយួន គេថាតែអ៊ីចឹង។

**ស៖** ចុះខ្លួនលោកផ្ទាល់ លោកមានទទួលបានព័ត៌មានណាមួយ ឬក៏លោកធ្លាប់និយាយជាមួយឪពុករបស់លោកទេ? ឬក៏ តើឪពុករបស់លោកធ្លាប់ប្រាប់លោកអំពីបញ្ហានេះដែរទេ?

**ឆ៖** អត់ៗៗមានទេបាទ។

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីឯកសារ E3/7960, ERN ជាភាសាអង់គ្លេស 00450295, បារាំង 0073899 *(ស៊ីក)*, ខ្មែរ 00851666 <និង 65>។ នេះជាកម្មាភិបាលមកពីកងពល៩២០ គាត់បានឆ្លើយពាក់ព័ន្ធទៅនឹងចលនា ខាំ ភួន៖ “ពួកគេបានលាក់ទុកអាវុធនៅក្នុងឃ្លាំង ហើយ ខាំ ភួន បានយកកងទ័ពវៀតណាម<ចូលមក>តាមរយៈ ស្វាយ យកមកលាក់នៅក្នុងទឹកដីយើង។ ស្វាយ គឺជាកម្មាភិបាលមកពីថ្នាក់ស្រុក” ហើយ<គាត់និយាយថា> “ពួកគេលាក់វៀតណាមទុកស្ងាត់ៗនៅក្បែរភូមិ។” បងស្រីរបស់លោកក៏និយាយថា អ្នកទាំងអស់នេះចិញ្ចឹមយួនដែរ។ តើចំណុចទាំងអស់នេះ លោកធ្លាប់ដឹង ធ្លាប់ឮអីដែរទេ?

[១៤:០៣:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

ខ្ញុំឮគឺការយោងទី២ ពាក់ព័ន្ធទៅនឹងបងស្រីរបស់គាត់ ហើយជាការយោងនេះ តើខ្ញុំស្ដាប់ឮត្រឹមត្រូវដែរទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ពិតហើយគឺឯកសារ E3/44, អង់គ្លេសទំព័រ៥ ERN 00295163។ ខ្ញុំមិនមានជាអត្ថបទភាសាខ្មែរ និងបារាំងទេ ពេលនេះ ជា ERN នោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី អ្វីដែលខ្ញុំទើបតែអានជូនលោកស្ដាប់នេះ ជាសកម្មភាពរបស់ ខាំ ភួន របស់ ស្វាយ, របស់ កាស៊ី ដែលនាំយោធាមកពីវៀតណាមហើយចិញ្ចឹមពួកគេ ហើយដឹកកាំភ្លើងអាវុធ មកឃ្លាំង។ តើនេះជាអ្វីៗដែលឪពុករបស់លោកបានប្រាប់លោក<>ទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** អាហ្នឹង យើងមិនឃើញជាក់លាក់ទេ គ្រាន់គេៗប្រកាសហ្នឹង វាគេប្រាប់ថាអ៊ីចឹងបាទ។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកកងពល៩២០ តើលោកបានដឹងអំពីប្រតិបត្តិការសឹកនៃកងពល ៩២០ នេះទេ? តើលោកស្គាល់អំពីរចនាសម្ព័ន្ធ តើកងពលនេះ យោធានៅក្នុងកងពលនោះគេប្រមូលមកពីណាជាដើម?

[១៤:០៥:១១]

**ឆ៖** ខ្ញុំអត់បាន -- អត់ដឹងពីរចនាសម្ព័ន្ធរបស់កងពលនោះទេ។

**ស៖** តើលោកធ្លាប់ដឹងអំពីចំនួនយោធា<សរុប>នៅក្នុងកងពល៩២០ ដែលត្រូវគេចាប់ខ្លួនដែរឬទេ? តើធ្លាប់ឮចំនួន<>សរុបគេចាប់ប៉ុន្មានទេ? មានចំនួនប៉ុន្មាន?

**ឆ៖** អត់មានបានដឹងទេបាទ។

**ស៖** តើលោកដឹងថា កងពល៩២០ នេះ ធ្លាប់ជាកងពលមកពីភូមិភាគឧត្តរ រួមជាមួយកងពល ៣១០ និងកងពល៤៥០ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងពីលេខរបស់កងពលចាស់អីទេបាទ ខ្ញុំស្គាល់តែមេៗ ព្រោះធ្លាប់ស្គាល់ ធ្លាប់ស្គាល់មេដូច តាឈិន, តាសយ អីធ្លាប់ស្គាល់គាត់បាទ។ បើថារចនាសម្ព័ន្ធផ្សេងៗ ខ្ញុំអត់ដែលដឹងទេ ពីព្រោះនៅក្មេងកាលជំនាន់ហ្នឹង។

**ស៖** តើលោកបានដឹងអ្វីអំពីទំនាក់ទំនងរវាង ឈិន មេបញ្ជាការកងពល៩២០ ហើយនិង អឿន ជាមេបញ្ជាការកងពល៣១០ ហើយនិង សឿន ក៏មេបញ្ជាការកងពល៤៥០<>ដែរឬទេ?

**ឆ៖** អត់បានដឹងទេបាទ។

**ស៖** តើលោកធ្លាប់ដឹងដែរទេថា ឈិន ត្រូវបានចាប់ខ្លួនប្រហែលជានៅក្នុងពេលជាមួយគ្នានឹង អឿន ហើយនិង សឿន <>ដែរ<ទេ>?

**ឆ៖** អត់បានដឹង ការចាប់ជាមួយគ្នាអីអត់ដឹងទេបាទ។

**ស៖** តើលោកធ្លាប់ឮ<>ថា អឿន, សឿន, ហើយនិង ឈិន គឺមានទំនាក់ទំនងជិតស្និទ្ធជាមួយ កុយ ធួន <>ដែរឬទេ?

[១៤:០៧:៥១]

**ឆ៖** ឮបាទ។

**ស៖** តើលោកបានដឹងអ្វីខ្លះអំពីទំនាក់ទំនងនេះ? ដឹងអ្វីខ្លះ?

**ឆ៖** ទំនាក់ទំនងពីលម្អិតនេះ អត់ដឹងទេ គ្រាន់តែដឹងទំនាក់ទំនង កុយ ធួន ហើយនិង តាឈិន អីហ្នឹង កាលជំនាន់ហ្នឹងនៅជាមួយគ្នាបាទ។

**ស៖** តើអ្នកណានៅជាមួយគ្នា? កុយ ធួន, អឿន, សឿន ហើយនិង ឈិន ឬក៏អ្នកណាខ្លះបាទ?

**ឆ៖** កាលខ្ញុំនៅតូចៗឃើញខ្ញុំស្គាល់គាត់ ឃើញតាមរយៈ ដែលៗឃើញគាត់មកនៅមណ្ឌលគិរី តាំងពី៦៧, ៦៨ ខ្ទង់ៗប៉ុណ្ណឹង។

**ស៖** ដើម្បីឲ្យប្រាកដ គឺថាលោកនិយាយថា “ពួកគេ”ហ្នឹង លោកនិយាយថា កុយ ធួន, អឿន, សឿន ហើយនិង ឈិន អ៊ីចឹងឬ?

**ឆ៖** បាទ។

**ស៖** ចុះអំពី យ៉ា វិញ តើគាត់មានទំនាក់ទំនងជាមួយ កុយ ធួន, អឿន, សឿន ហើយនិង ឈិន ដែរឬទេ?

**ឆ៖** អត់ដឹងដែរបាទ ប៉ុន្តែធ្លាប់ស្គាល់គ្នា។

**ស៖** ខ្ញុំសួរសំណួរជាក់លាក់ទៅលោកទាក់ទងទៅនឹង កុយ ធួន ហើយនិង យ៉ា។ តើលោកដឹងអ្វីខ្លះអំពីទំនាក់ទំនងរវាង កុយ ធួន និង យ៉ា ដែរឬទេ?

**ឆ៖** អត់ដឹងទេបាទ។

01239133



[១៤:០៩:៥៧]

**ស៖** តើធ្លាប់ឮមនុស្សម្នាក់ឈ្មោះ ចាន់ ចក្រី ដែរឬទេ?

**ឆ៖** ដែលឮ បាទ។

**ស៖** តើលោកបានដឹងអ្វីខ្លះ អំពី ចាន់ ចក្រី?

**ឆ៖** ឮដូចដែលឈ្មោះថាមេៗកងទ័ពខ្លាំងតែប៉ុណ្ណឹងទេ។

**លោក គង់ សំអុន៖**

លោកប្រធាន សូមអធ្យាស្រ័យ ដូចជាមានក្លិនអីចម្លែកក្នុងបន្ទប់ ដូចជាហ្គាសលេច ឬមួយយ៉ាងម៉េច។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលពិនិត្យមើល មានកើតអី មានទេ? ហើយមានក្លិនអី ក្លិនឈៀម ឬក៏ក្លិនហ្គាសអី?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ មិនថ្វីទេ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកដឹងទេថា លោក ចាន់ ចក្រី គឺជា<>មេ<បញ្ជាការ>កងពល ១៧០។ អ៊ីចឹងមែនឬទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** ដូចគេថាអ៊ីចឹងបាទ មែន តែខ្ញុំអត់ដែលស្គាល់គាត់ទេ ឮតែឈ្មោះ បាទ។

**ស៖** តើលោកដឹងដែរឬទេថា ចាន់ ចក្រី នោះ ពីដំបូងគាត់មកពីភូមិភាគឧត្តរ ដូចជា អឿន, សឿន ហើយនិង ឈិន ដែរ?

**ឆ៖** ឮតែឈ្មោះ តែមកពីណាពិតប្រាកដ ខ្ញុំអត់ៗអត់ចាំទេ។

[១៤:១២:២៤]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

ខ្ញុំមានសេចក្តីសង្កេត គឺថាឱ្យមេធាវីការពារក្តី <>ផ្អែកទៅលើអ្វីដែល<បានបង្កើតរួចហើយ គឺត្រូវ>សួរសំណួរបើក <ដូចជាថា “តើលោកដឹងទេ>ថាតើ ចាន់ ចក្រី មកពីណា? <គាត់>ឆ្លើយថាមិន

ដឹងទេ។ <លោកអាចផ្តល់ព័ត៌មានទៅឲ្យសាក្សីតាមដែលលោកចង់បាន ហើយលោកផ្តល់>លេខយោងជាឯកសារ<នោះទៅ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្រប។ ខ្ញុំជឿថា ចម្លើយគឺគាត់ឆ្លើយរួចហើយ ថាគាត់មិនដឹង<ទេ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឮអំពីការចូលរួមរបស់កងពល៣១០ កងពល៤៥០ ហើយនិងកងពល៩២០ ក្នុងការធ្វើផែនការវាយប្រហារព្រលានយន្តហោះពោធិ៍ចិនតុង ហើយនិងវិទ្យុភ្នំពេញ ហើយនិងផែនការធ្វើរដ្ឋប្រហារប្រឆាំងរដ្ឋាភិបាល ហើយនិងការពាក់ព័ន្ធទៅនឹងការបះបោររបស់កងពលទាំងនេះ តើលោកធ្លាប់ឮអ្វីៗពីរឿងទាំងនេះទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់ដែលបានឮទេ។

**ស៖** តើលោកធ្លាប់ឮ<ទេ>ថា មូលហេតុ<>អ្វីបានជាគេចាប់ខ្លួន ឈិន?

**ឆ៖** ដែលគេប្រកាសហ្នឹង អ្នកខ្លះគេ គេថាខ្សែយួន ខ្លះគេថា សេ.អ៊ី.អា។ ខ្ញុំក៏មិនយល់ដែរ គេនិយាយតែអ៊ីចឹង សេ.អ៊ី.អា ផង, កា.ហ្សេ.បេ ផង, យួន ផង។

[១៤:១៤:៤៥]

**ស៖** តើលោកធ្លាប់ឮអំពីហេតុការណ៍ដែលបាញ់អាវុធ បាញ់នៅសាលាសិល្បៈ នៅជិតរាជវាំងដើមឆ្នាំ១៩៧៦ ហើយនិងការគប់គ្រាប់បែក<ទេ>? តើលោកធ្លាប់ឮហេតុការណ៍<ទាំង>នេះដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលឮទេបាទ។

**ស៖** បាទ តើត្រឹមត្រូវដែរឬទេ លោកសាក្សី ដែលលោកថាមិនដឹងអ្វីអំពីសេចក្តីលម្អិតពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ តើខ្ញុំសង្ខេបអ៊ីចឹងត្រឹមត្រូវពីលោកដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ សាក្សីបានឆ្លើយច្បាស់ហើយជាក់លាក់នូវព័ត៌មានហ្នឹងរួចហើយ ទាំងពេលដែលគាត់ធ្វើសក្ខីកម្មដែលទាក់ទងទៅនឹងបញ្ហាសន្តិសុខ។ <ដូច្នេះ

បើ>មេធាវី<មានសំណួរ>ជាក់លាក់បន្ថែម <គាត់គួរតែសួរអំ>ពីបញ្ហាសន្តិសុខហ្នឹង។ <ខ្ញុំគិតថា គាត់មានការអនុញ្ញាតឲ្យធ្វើដូច្នេះ។> ប៉ុន្តែ<ការព្យាយាមឲ្យ>សាក្សី<អះអាងថា គាត់>មិនដឹង<អ្វីមួយចំពោះសក្ខីកម្មដែលគាត់បានផ្ដល់រួចហើយ ខ្ញុំជឿថា មិនជាការល្អទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ហើយពីការជំទាស់នេះ ប៉ុន្តែខ្ញុំគ្រាន់តែសួរព័ត៌មានលម្អិតបន្ថែមទៀតពីសាក្សី ពីព្រោះម៉្យាងទៀត គឺថាសាក្សីទំនងជាបង្ហាញថា នួន ជា ផ្ដល់ដំណឹងទៅឲ្យគាត់ គឺថាខ្ញុំប្រើបញ្ហាទូទៅអំពីបញ្ហាសន្តិសុខ។ ខ្ញុំចង់ដឹងថាតើគាត់ដឹងអ្វីច្បាស់លាស់ដែរឬទេ។ <នេះហើយជា>មូលហេតុដែលខ្ញុំសួរហ្នឹង <ហើយវាហាក់ដូចជា>គាត់<មិន>ដឹងរឿង<អ្វីទាំងអស់>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំយល់ថាលោកមេធាវីដូចជាដើរផ្លូវមួយពង្វាង។ <ដូច្នេះ វាអាចនឹងបំពេញចិត្តព្រះរាជអាជ្ញា> បើសិនជាសំណួរហ្នឹង<ត្រូវបាន>រៀប<ឡើងវិញដូចតទៅនេះ "តើ>លោកមាន<ព័ត៌មាន>បន្ថែមទៀតដែរឬទេ បន្ថែមទៅលើអ្វីដែល<លោកបាននិយាយរួចហើយ>ទាក់ទងទៅនឹងបញ្ហាសន្តិសុខ?" <ដូច្នេះ វាមិនកែ>អ្វីដែលគាត់បានឆ្លើយកន្លងមកនេះ<ទេ>។ ខ្ញុំមិនច្បាស់ថាតើលោកចង់ដើរផ្លូវណានោះទេ ខ្ញុំមិនទាន់ដឹងច្បាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែព្យាយាមដើម្បី<>មើល<កម្រិតនៃ>ការយល់ដឹងរបស់គាត់ ហើយនិងការដឹងឮរបស់គាត់ ប៉ុន្តែខ្ញុំ<គិតថា ខ្ញុំ>ត្រូវបោះបង់ការព្យាយាមនេះចោល <ព្រោះ>គាត់មិនដឹង<អ្វីទាំងអស់>។

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

[១៤:១៨:០៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01239136



**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី! ខ្ញុំ គង់ សំអុន ជាសហមេធាវីជាតិការពារលោក ខៀវ សំផន។ ខ្ញុំមានសំណួរខ្លីទេ។ ទី១ ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីមន្ទីររបស់ ពូសុភា ដែលលោកហៅថាមន្ទីរពូសុភា។ នៅពេលដែលលោកនៅតំបន់១០៥ តើលោកស្គាល់ថាមន្ទីរពូសុភា នេះជាអ្វីដែរ លោកអាចបញ្ជាក់បានទេ?

លោកប្រធានប្រហែលជាអស់ថ្មទេដឹង ឬមួយយ៉ាងម៉េចអត់ឃើញឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី តើលោកស្តាប់ឮទេ ឬក៏មានបញ្ហាអ្វី?

**លោក ផាន វ៉ាន៖**

អំមិញឆ្លើយហើយតើ បានដឹង។

**ប្រធានអង្គជំនុំ៖**

បាទ នៅឆ្លើយបាន។ សូមអញ្ជើញបន្តទៀត ក្រែងលមានបញ្ហាកាសអីទេ បញ្ហាថ្ម។

សូមអញ្ជើញៗ សួរតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មី លោកមេធាវី គង់ សំអុន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំសួរអំពីមន្ទីរពូសុភា ដែលលោកឆ្លើយថាមន្ទីរពូសុភា លោកស្គាល់នៅពេលដែលលោកនៅតំបន់១០៥។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើមន្ទីរនោះជាមន្ទីរអីដែរ លោកដឹងទេ អង្កាល់ដែលលោកនៅតំបន់១០៥?

**លោក ផាន វ៉ាន៖**

**ឆ៖** អង្កាល់នុំងគេហៅមន្ទីរពូសុភាហ្នឹងកន្លែងយោធាគេ យោធាតំបន់ ហើយនិងកន្លែងសន្តិសុខ។

**ស៖** សម្រាប់លោកផ្ទាល់ លោកដែលទៅដល់កន្លែងមន្ទីរ ពូសុភា ហ្នឹងដែរឬទេ?

**ឆ៖** កាលជំនាន់នុំងធ្លាប់ទៅដែរតើ។

**ស៖** លោកអាចបញ្ជាក់ លោកទៅទីតាំងកន្លែងណា? លោកសាក្សី លោកឮខ្ញុំនិយាយទេ?

**ឆ៖** អត់ៗឮផងបាទ។ សូមឲ្យសួរម្តងទៀតមកបាទ។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់សួរបញ្ជាក់អំពីមន្ទីរ ពូសុភា ហើយខ្ញុំចង់សួរថា តើមន្ទីរហ្នឹង

លោកធ្លាប់ទៅទេ? ហើយលោកឆ្លើយថា លោកធ្លាប់ទៅ ហើយខ្ញុំសួរបន្ថែមថា នៅក្នុងមន្ទីរហ្នឹង ដែលលោកទៅហ្នឹង លោកទៅត្រង់ណាកន្លែងជាក់លាក់ ទីតាំងជាក់លាក់នៃមន្ទីរពូសុភា ហ្នឹងណា?

**ឆ៖** អាហ្នឹងចាំអត់បាន ព្រោះវាដូរភូមិសាស្ត្រអស់ហើយបាទ។ វានៅក្នុងរង្វង់ភ្នំក្រោលដូចតែគ្នាបាទ។

[១៤:២១:៥៥]

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E3/57 ជាសក្ខីកម្មរបស់លោក នៅក្នុង ERN ជាភាសាខ្មែរ 00287705, ភាសាបារាំង 00353104, ភាសាអង់គ្លេស 00290508។ ខ្ញុំសូមដកស្រង់ជូន ៖ “សួរ៖ តើលោកមានធ្លាប់ទៅមើលមន្ទីរសន្តិសុខនោះដែរឬទេ? ឆ្លើយ៖ ខ្ញុំមិនដែលទៅទេ ហើយទន្ទឹមនឹងនោះ មានចម្ងាយប្រហែល៧គីឡូម៉ែត្រពីមន្ទីរក-១៧”។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចនេះ ពីព្រោះនៅពេលដែលលោកផ្តល់សក្ខីកម្មមុនលោកថា លោកអត់ដែលទៅទេ ហើយអំមិញលោកថាលោកធ្លាប់ទៅ។ លោកអាចបញ្ជាក់បានទេ តើមួយណាត្រឹមត្រូវ?

**ឆ៖** ទៅនោះបានន័យថា ឆាបចុះឆាបឡើង យើងដើរតាមផ្លូវណាបាទ មិនមែនទៅនៅហ្នឹងទេ។ គ្រាន់តែឆ្លងកាត់ហ្នឹង របៀបថាឆ្លងកាត់ហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា លោកមិនដែលចូលទៅក្នុងបរិវេណមន្ទីររបស់ពូសុភានោះទេ?

**ឆ៖** មិនដែលចូលក្នុងបរិវេណគេទេបាទ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀតទាក់ទងទៅនឹងឈ្មោះ ឡេង ហើយនិង ពូសុភា មុននេះលោកនិយាយថា ក្រោយពីចាប់ សុភា ទៅ ឡេង នេះមកជំនួស គ្រប់គ្រងនៅក្នុងមន្ទីរហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោកថា លោកដឹងថា ឡេង មកជំនួសសុភា ហ្នឹងដោយរបៀបណាដែរ មានអ្នកណាជាអ្នកប្រាប់លោក ឬក៏មានអ្វីដែលផ្តល់ជាព័ត៌មានឲ្យលោកដឹងពីព័ត៌មាននេះ? លោកអាចបញ្ជាក់បានទេ?

[១៤:២៤:២៨]

**ឆ៖** អាហ្នឹងគេដឹង គេប្រកាសទូទៅតែម្តងបាទ។

**ស៖** គេប្រកាសយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

**ឆ៖** ប្រកាស គេប្រជុំ។

**ស៖** បាទ លោកអរគុណ។ លោកអាចបញ្ជាក់អំពីតួនាទីរបស់ ឡេង ហ្នឹងបានទេ គាត់មាន

ឋាន:ឬក៏តួនាទីអ្វីដែរ នៅពេលដែលលោកនៅតំបន់១០៥ហ្នឹង?

**ឆ៖** អាហ្នឹងគេទទួលខាងសន្តិសុខបាទ។

**ស៖** បាទ ចុះ សុភា – ពូសុភា ដែលលោកនិយាយហ្នឹង?

**ឆ៖** គេធំលើហ្នឹងទៀត។ ដល់គេដក ពូសុភា ទៅ គេឡើងជំនួស ពូសុភា វិញ ហើយក្រោយមកទៀតមានដាក់ផ្សេងៗទៀត ខ្ញុំអត់ៗដឹងទេ។

**ស៖** លោកអាចបញ្ជាក់ពីការតែងតាំងហ្នឹងបានទេ លោកនិយាយថា ប្រជុំហ្នឹងអ្នកណាជាអ្នកចាត់តាំង ឬក៏តែងតែឲ្យ ឡេង ទៅជាមួយ សុភា ហ្នឹង លោកដឹងទេ?

**ឆ៖** អត់ៗដឹងទេ ពីព្រោះអត់មានពិធីអីទេ គ្រាន់តែគេប្រកាសពេលប្រជុំអ៊ីចឹង យើងគេប្រកាសអ៊ីចឹងតែម្ដង។

**ស៖** បាទ សូមអរគុណ។ លោកនិយាយគេប្រកាសហ្នឹង "គេ"ហ្នឹង គេណា លោកអាចបញ្ជាក់ច្បាស់បានទេ?

**ឆ៖** នៅក-១៧ហ្នឹង ប្រធានមន្ទីរហ្នឹងគេប្រជុំប្រកាសប្រាប់អ៊ីចឹងតែម្ដងបាទ។

**ស៖** លោកចូលរួមក្នុងការប្រជុំហ្នឹងដែរ ឬមួយយ៉ាងម៉េច?

**ឆ៖** អាហ្នឹងគេហៅទាំងអស់គ្នាទៅប្រជុំប្រកាសប្រាប់ ព្រោះរឿងហ្នឹងវាវែងឆ្ងាយ ទាល់តែរៀបរាប់វែងឆ្ងាយបានយល់បាទ។ ព្រោះការប្រជុំហ្នឹង មានប្រជុំណែនាំ ប្រជុំណែនាំហើយ ចុងក្រោយគឺប្រកាសប្រាប់ថាអ្នកនេះក្បត់ អ្នកនោះក្បត់អ៊ីចឹងទៅ។ ហើយអ្នកណាមកៗជំនួសអ៊ីចឹង គេប្រាប់តែប៉ុណ្ណឹង។ អាហ្នឹងឧទាហរណ៍អ៊ីចឹងបាទ។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំសួរថា លោកចូលរួមនៅក្នុងការប្រជុំនោះដែរទេ? លោកស្ដាប់បានទេ?

**ឆ៖** ចូល កាលនោះស្ដាប់គេទាំងអស់ហ្នឹង។

[១៤:២៧:១៧]

**ស៖** លោកអាចបញ្ជាក់បានទេថា ហេតុអីបានជាការចាត់តាំង ឬក៏តែងតាំងផ្នែកយោធា លោកទៅចូលរួមប្រជុំហ្នឹងដែរ?

**ឆ៖** អានេះមិនមែនតែងតាំងទេបាទ អានេះគឺប្រជុំប្រកាស ៗថាអ្នកនេះក្បត់ អ្នកនោះក្បត់ ហើយអ្នកនេះឡើងមកជំនួស គេប្រកាសអ៊ីចឹង។ ការតែងតាំងនោះ យើងមិនដឹងទេ។ ខាងក្រោមៗ អត់

ដែលដឹងទេ អាហ្នឹងរឿងមេខាងលើ។ អ៊ីចឹងសូមបញ្ជាក់អ៊ីចឹងឲ្យលោកយល់បាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណលោក ផាន វ៉ាន សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីបានដល់ពេលនេះដល់ទីបញ្ចប់ហើយ សក្ខីកម្មរបស់លោកអាចនឹងរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយនាពេលនេះ លោកអាចសម្រាកបានហើយ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខសេចក្តីចម្រើន។

**លោក ផាន វ៉ាន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរលោក ជួង សុភារិទ្ធ បុគ្គលិកអង្គការ -- បុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលបានជួយសម្របសម្រួលដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះតាមរយៈប្រព័ន្ធសោតទស្សន៍ប្រព្រឹត្តទៅបានល្អតាំងពីដំបូង រហូតដល់ចប់នៅពេលនេះ។ ហើយលោកអាចសម្រាកបានហើយ។

[១៤:២៨:៤៤]

ហើយអង្គជំនុំជម្រះ -- សវនាការនៅថ្ងៃគឺដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៨ ខែមេសា ឆ្នាំ២០១៦ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការចាប់ពីថ្ងៃចន្ទ ទី១៨ ខែមេសា ឆ្នាំ ២០១៦ តទៅ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខស-២១។ ហើយនៅសវនាការនៅថ្ងៃចន្ទ ទី១៨ ខែមេសា ឆ្នាំ២០១៦ ក្រោយចូលឆ្នាំខ្មែរនោះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម -- ស្តាប់ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-243 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី១៨ ខែមេសា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៣០នាទី)*